ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២០ លេខ៨៣ ត្រីមាសទី០៤ ឆ្នាំ២០២០

# រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច បទបញ្ជា សារាចរ ប្រកាស

# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


១៤-១១-២០២០ -ព្រះរាជក្រម នស/រកម/១១២០/០២៤ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន *(តទៅរាជកិច្ចលេខ ៨៤)* ១០១៨៧


### ២~ព្រះរាជក្រឹត្យ


២-១១-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១១២០/១១៧៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ចាវ ហ៊ួយ (XIAO, HUI)** ជនជាតិចិន សញ្ជាតិចិន ដោយប្តូរឈ្មោះជា **ស៊ី ឈៀន (SHI QIANG)** ១០២៧១

២-១១-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១១២០/១១៧៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **វ៉ាង ជីឆៀង (WANG, JIQIANG)** ជនជាតិចិន សញ្ជាតិចិន ១០២៧២

២-១១-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១១២០/១១៧៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ម៉ោវ យ៉ាស៊ាំង (MAO, YAXIONG)** ជនជាតិចិន សញ្ជាតិចិន ១០២៧៣

២-១១-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១១២០/១១៧៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **លី ស៊័ង (LI, SHUANG)** ជនជាតិចិន សញ្ជាតិចិន ដោយប្តូរឈ្មោះជា **រ៉េ អាឡេន (RAY ALLEN)** ១០២៧៤

៤-១១-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១១២០/១១៨០ ស្តីពី ការដាក់ឱ្យចូលនិវត្តន៍នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ២៨ រូប ១០២៧៥

៤-១១-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១១២០/១១៨១ ស្តីពី ការតែងតាំងឯកឧត្តម **សុខ លូ** ជាអភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល ១០២៧៨

៤-១១-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១១២០/១១៨២ ស្តីពី ការផ្តល់គោរមងារលោក **យុនថាវខ្សេផងផាន់** ជា ឧកញ៉ា ១០២៧៩

៤-១១-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១១២០/១១៨៣ ស្តីពី ការផ្តល់គោរមងារលោក **វឿន ឧុទ្ធី** ជា ឧកញ៉ា ១០២៨០

៤-១១-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១១២០/១១៨៤ ស្តីពី ការផ្តល់គោរមងារអ្នកស្រី **ឡាយ ពេជ្រសុវណ្ណារ័ត្ន** ជា ឧកញ៉ា ១០២៨១

៤-១១-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១១២០/១១៨៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ ដល់លោក **ដារក អាលេកហ្សេនដ័រ ហ្វិលលិប ដេវិត (DARROCH ALEXANDER PHILIP DAVID)** ជនជាតិអង់គ្លេស សញ្ជាតិអង់គ្លេស ១០២៨២

៤-១១-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១១២០/១១៨៦ ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌទៅក្នុង ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដល់មន្ត្រីរាជការ ៥៥៦ រូប ១០២៨៣

## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ

១៦-១០-២០២០ -អនុក្រឹត្យលេខ ៨៨៦ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ ១០៣០១

១៦-១០-២០២០ -អនុក្រឹត្យលេខ ៨៨៧ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ ១០៣០៣

១៦-១០-២០២០ -អនុក្រឹត្យលេខ ៨៨៨ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ ១០៣០៤

១៦-១០-២០២០ -អនុក្រឹត្យលេខ ៨៨៩ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ ១០៣០៥

១៦-១០-២០២០ -អនុក្រឹត្យលេខ ៨៩០ អនក្រ.តត ស្តីពី ការនិយ័តកម្ម ក្របខ័ណ្ឌតម្លើងឋានន្តរស័ក្តិ និងថ្នាក់ជូនមន្ត្រីរាជការ ១០៣០៦

១៦-១០-២០២០ -អនុក្រឹត្យលេខ ៨៩១ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ១០៣០៨

១៩-១០-២០២០ -អនុក្រឹត្យលេខ ៨៩២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១០៣០៩

១៩-១០-២០២០ -អនុក្រឹត្យលេខ ៨៩៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១០៣១១

# ព្រះរាជក្រម

នស/រកម/១១២០/០៤៨

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៦ ខែតុលា ឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អាស៊ាន-ហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន

**មាត្រា១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន ដែលបានចុះហត្ថលេខានៅរដ្ឋធានីណៃពិដោនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។

ថ្ងៃ សៅរ៍ ៨ រោច ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០២០

នស/រកម/១១២០/០២៥

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៨៣ សប្រ

*រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ២០១៧*

## សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាព នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ២០/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## រាជរដ្ឋាភិបាល

ប្រគល់សិទ្ធិពេញសមត្ថភាពជូន ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន។

ក្នុងករណីដែលឯកឧត្តម **ប៉ាន សូរស័ក្តិ** មានធុរៈដោយថាហេតុ ឯកឧត្តមអាចផ្ទេរសិទ្ធិនេះបាន។

ដើម្បីជាសក្ខីភាព នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិពេញលេញតាមអំណាចច្បាប់ បានចុះហត្ថលេខាលើសិទ្ធិប្រទាននេះ។

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា
*Kingdom of Cambodia*

រាជរដ្ឋាភិបាល
*Royal Government*

ជាតិ សាសនា ព្រះមហាក្សត្រ
*Nation Religion King*

N. 89 DFP

Phnom Penh, 8 November 2017

**DELEGATION OF FULL POWERS**

- Considering the Constitution of the Kingdom of Cambodia,
- Considering the Royal Decree NS/RKT/0913/903 dated 24 September 2013 on the Nomination of the Royal Government of Cambodia,
- Considering the Royal Decree NS/RKT/0416/368 dated 04 April 2016 on the Reshuffle of the Royal Government of Cambodia,
- Considering the Royal Kram 02/NS/94 dated 20 July 1994 on the promulgating the Law on the Organization and Functioning of Council of Ministers,
- Considering the Royal Kram NS/RKM/0196/16 dated 24 January 1996 promulgating the Law on the Establishment of the Ministry of Commerce,
- Pursuant to the Proposal of the Minister of Commerce,

**THE ROYAL GOVERNMENT**

Delegates herewith Full Powers to His Excellency **PAN SORASAK**, Minister of Commerce, to sign, on behalf of the Royal Government of Cambodia, the ASEAN-Hong Kong, China Free Trade Agreement.

These Powers include the Power of Delegation.

In witness whereof, the undersigned, the Prime Minister of the Kingdom of Cambodia, with Full Powers duly entrusted to him, has signed the Delegation of Full Powers.

**Prime Minister**

**Samdech Akka Moha Sena Padei Techo Hun Sen**

# កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី
# អាស៊ាន-ហុងកុង នៃប្រទេសចិន

## មាតិកា


បុព្វកថា

ជំពូក១ ការបង្កើតតំបន់ពាណិជ្ជកម្មសេរី គោលបំណង និយមន័យទូទៅ និងការបកស្រាយ

ជំពូក២ ពាណិជ្ជកម្មទំនិញ

ឧបសម្ព័ន្ធ ២-១ (តារាងកម្មវិធីពន្ធគយ)

ជំពូក៣ វិធានដើមកំណើត

ឧបសម្ព័ន្ធ ៣-១ (នីតិវិធីប្រតិបត្តិវិញ្ញាបនបត្រដើមកំណើត)

សេចក្តីបន្ថែម (បញ្ជីទិន្នន័យត្រូវការចាំបាច់)

ឧបសម្ព័ន្ធ ៣-២ (វិធានផលិតផលជាក់លាក់)

ឧបសម្ព័ន្ធ ៣-៣ (វិធានផលិតផលជាក់លាក់ដែលត្រូវពិនិត្យឡើងវិញ)

ជំពូក៤ នីតិវិធីគយនិងកិច្ចសម្រួលពាណិជ្ជកម្ម

ជំពូក៥ វិធានការអនាម័យនិងភូតគាមអនាម័យ

ជំពូក៦ ស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃអនុលោមភាព

ជំពូក៧ ឧបាស្រ័យពាណិជ្ជកម្ម

ជំពូក៨ ពាណិជ្ជកម្មសេវាកម្ម

ឧបសម្ព័ន្ធ ៨-១ (តារាងសន្យាតាមវិស័យ)

ជំពូក៩ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេស

ជំពូក១០ កម្មសិទ្ធិបញ្ញា

ជំពូក១១ បទប្បញ្ញត្តិទូទៅនិងការលើកលែង

ជំពូក១២ បទប្បញ្ញត្តិរៀបចំអង្គភាព

ជំពូក១៣ ការពិគ្រោះយោបល់និងការដោះស្រាយវិវាទ

ឧបសម្ព័ន្ធ ១៣-១ (វិធាននៃនីតិវិធីសម្រាប់ដំណើរការនីតិវិធីវេទិកាមជ្ឈត្តកម្ម)

ជំពូក១៤ អវសានប្បញ្ញត្តិ




ɥ

## បុព្វកថា

រដ្ឋាភិបាលនៃបណ្តារដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍រួមមាន ព្រុយណេ ព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") សាធារណរដ្ឋឥណ្ឌូណេស៊ី ("ឥណ្ឌូណេស៊ី") សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ("ឡាវ") ម៉ាឡេស៊ី សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ("មីយ៉ាន់ម៉ា") សាធារណរដ្ឋហ្វីលីពីន ("ហ្វីលីពីន") សាធារណរដ្ឋសិង្ហបុរី ("សិង្ហបុរី") ព្រះរាជាណាចក្រថៃ ("ថៃ") និងសាធារណរដ្ឋសង្គមនិយមវៀតណាម ("វៀតណាម") (ដែលតទៅនេះហៅកាត់រួមគ្នាថា "បណ្តារដ្ឋសមាជិកអាស៊ាន" និងហៅដោយឡែកពីគ្នាថា "រដ្ឋសមាជិកអាស៊ាន") និងរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន ("ហុងកុង នៃប្រទេសចិន")

**ដែលជំរុញដោយ** មិត្តភាព កិច្ចសហប្រតិបត្តិការ ទំនាក់ទំនងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការវិនិយោគ ដែលមានការកើនឡើង

**ដោយមានបំណង** កាត់បន្ថយរបាំងនានា ដែលរាំងស្ទះដល់លំហូរពាណិជ្ជកម្មទំនិញនិងសេវាកម្ម ព្រមទាំងការវិនិយោគឱ្យមកនៅតិចបំផុត ពង្រីក និងធ្វើឱ្យទំនាក់ទំនងសេដ្ឋកិច្ចក្នុងចំណោមភាគីកាន់តែស៊ីជម្រៅ បន្ទាបថ្លៃដើមក្នុងការធ្វើធុរកិច្ច បង្កើនពាណិជ្ជកម្ម លើកកម្ពស់ប្រសិទ្ធភាពសេដ្ឋកិច្ចនិងបង្កើតទីផ្សារឱ្យកាន់តែធំទូលាយជាមួយនឹងកាលានុវត្តភាពកាន់តែច្រើន និងសេដ្ឋកិច្ចមាត្រដ្ឋានកាន់តែប្រសើរសម្រាប់ការធ្វើធុរកិច្ច

**ដោយជឿជាក់ថា** កិច្ចព្រមព្រៀង ដែលបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង នៃប្រទេសចិននឹងពង្រឹងភាពជាដៃគូសេដ្ឋកិច្ចនិងដើរតួជាប្លុកដ៏សំខាន់មួយ ឆ្ពោះទៅរកការធ្វើសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព

**ដោយទទួលស្គាល់** តួនាទីដ៏សំខាន់ និងការចូលរួមចំណែករបស់អាជីវកម្មនៅក្នុងការលើកកម្ពស់ពាណិជ្ជកម្ម និងការវិនិយោគក្នុងចំណោមបណ្តាភាគី និងភាពចាំបាច់ក្នុងការបន្តជំរុញ និងសម្របសម្រួលបន្ថែមទៀតលើកិច្ចសហប្រតិបត្តិការនិងការទាញយកប្រយោជន៍ពីឱកាសអាជីវកម្មកាន់តែច្រើន ដែលផ្តល់ដោយកិច្ចព្រមព្រៀងនេះ

**ដោយទទួលស្គាល់** កម្រិតខុសៗគ្នានៃការអភិវឌ្ឍសេដ្ឋកិច្ចក្នុងចំណោមបណ្តារដ្ឋសមាជិកអាស៊ាននិងរវាងបណ្តារដ្ឋសមាជិកអាស៊ាននិងហុងកុង នៃប្រទេសចិននិងភាពចាំបាច់ក្នុងការផ្តល់ភាពទន់ភ្លន់ រួមទាំងប្រព្រឹត្តកម្មពិសេសនិងដោយឡែក ជាពិសេសសម្រាប់រដ្ឋសមាជិកអាស៊ានថ្មី ព្រមទាំងភាពចាំបាច់ក្នុងការសម្រួលដល់ការចូលរួមកាន់តែច្រើននៃរដ្ឋសមាជិកអាស៊ានថ្មីនៅក្នុងកិច្ចព្រមព្រៀងនេះ និងការពង្រីកការនាំចេញ រួមមាន តាមរយៈការពង្រឹងសមត្ថភាព ប្រសិទ្ធភាព និងភាពប្រកួតប្រជែងក្នុងស្រុករបស់ខ្លួន ជាដើម

**ដោយអះអាងជាថ្មី** អំពីសិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់បណ្តាភាគីក្រោមកិច្ចព្រមព្រៀងWTO និងកិច្ចព្រមព្រៀង និងកិច្ចរៀបចំអន្តរជាតិ ដែលមានស្រាប់ផ្សេងទៀត និង

**ដោយទទួលស្គាល់** សន្ទុះជាវិជ្ជមានដែលកិច្ចព្រមព្រៀង និងកិច្ចរៀបចំពាណិជ្ជកម្មថ្នាក់តំបន់អាចជួយពន្លឿនការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មក្នុងតំបន់និងពិភពលោក និងតួនាទីដ៏សំខាន់របស់កិច្ចព្រមព្រៀង និងកិច្ចរៀបចំទាំងនោះក្នុងការដើរតួជាប្លុកសម្រាប់ប្រព័ន្ធពាណិជ្ជកម្មពហុភាគី

**បានព្រមព្រៀងគ្នាដូចខាងក្រោម៖**

## ជំពូក១

## ការបង្កើតតំបន់ពាណិជ្ជកម្មសេរី

## គោលបំណង និយមន័យទូទៅ និងការបកស្រាយ

### មាត្រា១

### ការបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង នៃប្រទេសចិន

បណ្តាភាគីសម្រេចបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង នៃប្រទេសចិន ស្របតាមមាត្រា XXIV នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្ម (GATT) ឆ្នាំ១៩៩៤ និងមាត្រា V នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម (GATS)។

### មាត្រា២

### គោលបំណង

គោលបំណងនៃកិច្ចព្រមព្រៀងនេះគឺដើម្បីៈ

(ក) ធ្វើសេរីភាវូបនីយកម្មនិងសម្រួលពាណិជ្ជកម្មទំនិញជាបន្តបន្ទាប់ក្នុងចំណោមបណ្តាភាគី តាមរយៈការលុបបំបាត់របាំងពន្ធគយនិងមិនមែនពន្ធគយលើទំនិញភាគច្រើនក្នុងពាណិជ្ជកម្មទំនិញក្នុងចំណោមបណ្តាភាគី ជាដើម

(ខ) ធ្វើសេរីភាវូបនីយកម្មនិងសម្រួលដល់ពាណិជ្ជកម្មសេវាកម្មជាបន្តបន្ទាប់ ដោយគ្របដណ្តប់លើវិស័យជាច្រើនក្នុងចំណោមបណ្តាភាគី

(គ) ជំរុញនិងលើកកម្ពស់ឱកាសវិនិយោគ

(ឃ) ពង្រឹង ធ្វើពិពិធកម្ម និងលើកកម្ពស់ទំនាក់ទំនងពាណិជ្ជកម្ម ការវិនិយោគ និងសេដ្ឋកិច្ចរវាងបណ្តាភាគី និង

(ង) ផ្តល់ប្រព្រឹត្តកម្មពិសេសនិងដោយឡែកដល់រដ្ឋសមាជិកអាស៊ាន ជាពិសេសរដ្ឋសមាជិកអាស៊ានថ្មី ដើម្បីសម្រួលដល់ការធ្វើសមាហរណកម្មសេដ្ឋកិច្ចឱ្យកាន់តែមានប្រសិទ្ធភាព។

### មាត្រា៣

### ទំនាក់ទំនងទៅនឹងកិច្ចព្រមព្រៀងផ្សេងទៀត

១- ភាគីនីមួយៗអះអាងអំពីសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនពាក់ព័ន្ធនឹងភាគីផ្សេងទៀតក្រោមកិច្ចព្រមព្រៀង WTO និងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀតដែលភាគីទាំងពីរជាហត្ថលេខី។

២- ពុំមានប្រការណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះត្រូវបានបកស្រាយដើម្បីធ្វើអញ្ញត្តិកម្មសិទ្ធិ (ដកហូតសិទ្ធិ) ឬកាតព្វកិច្ចរបស់ភាគីណាមួយពាក់ព័ន្ធនឹងភាគីផ្សេងទៀតឡើយ ក្រោមកិច្ចព្រមព្រៀង WTO និងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀតដែលភាគីទាំងពីរជាហត្ថលេខី។

៣- ក្នុងករណីមានភាពមិនស្របគ្នារវាងកិច្ចព្រមព្រៀងនេះនិងកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀត ដែលភាគីពីរឬច្រើនជាហត្ថលេខី បណ្តាភាគីទាំងនោះត្រូវពិគ្រោះយោបល់ភ្លាមៗ ដើម្បីស្វែងរកដំណោះស្រាយដែលពេញចិត្តទៅវិញទៅមក។

## មាត្រា៤

## និយមន័យនៃការអនុវត្តទូទៅ

សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ លើកលែងតែមានបរិបទតម្រូវផ្ទុយពីនេះ នោះវាក្យសព្ទ៖

ក) **កិច្ចព្រមព្រៀង** មានន័យថា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង នៃប្រទេសចិន។

ខ) **កិច្ចព្រមព្រៀងវិនិយោគ AHK** មានន័យថា កិច្ចព្រមព្រៀងស្តីពីការវិនិយោគក្នុងចំណោមរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន និងរដ្ឋជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍។

គ) AHKFTA មានន័យថា តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង នៃប្រទេសចិន។

ឃ) **គណៈកម្មាធិការចម្រុះ AHKFTA** មានន័យថា គណៈកម្មាធិការចម្រុះតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង នៃប្រទេសចិន ដែលត្រូវបានបង្កើតឡើងអនុលោមតាមមាត្រា១ (គណៈកម្មាធិការចម្រុះ AHKFTA) នៃជំពូក១២ (បទប្បញ្ញត្តិស្តីពីអង្គភាព)។

ង) **តំបន់** នៃ៖

(i) រដ្ឋសមាជិកអាស៊ាននីមួយៗមានន័យថាជា ដែនដីរបស់ខ្លួន និង

(ii) ហុងកុង ប្រទេសចិន មានន័យថាតំបន់រដ្ឋបាលពិសេសហុងកុង ដែលបញ្ជាក់ដោយបទបញ្ជារបស់ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតចិន លេខ២២១ ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៩៧ ដែលរួមមានកោះហុងកុង តំបន់ខូវលូន (Kowloon) និងតំបន់ថ្មីៗ។

ច) **អាស៊ាន** មានន័យថា សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍។

ឆ) **ពន្ធគយ** មានន័យថា ពន្ធឬការយកថ្លៃប្រភេទណាមួយរួមទាំងពន្ធ ឬក៏ការគិតថ្លៃបន្ថែមលើការនាំចូលទំនិញ ប៉ុន្តែមិនរាប់បញ្ចូល៖

(i) អាករផ្សេងៗទៀតដែលដូចគ្នានឹងពន្ធក្នុងស្រុក រួមទាំងពន្ធអាករ ពន្ធលើការលក់ ពន្ធលើទំនិញនិងសេវាកម្មដែលបានកំណត់ស្របតាមបទប្បញ្ញត្តិនៃកថាខណ្ឌ២ នៃមាត្រា III នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ ពាក់ព័ន្ធនឹងផលិតផលក្នុងស្រុកដែលដូចគ្នា ឬពាក់ព័ន្ធមាត្រាដែលផលិតផលនាំចូលនោះត្រូវបានផលិត ឬបង្កើតឡើងទាំងស្រុង ឬដោយផ្នែក។

(ii) ការប្រឆាំងការលក់បង្ខូចថ្លៃឬពន្ធប៉ះប៉ូវ ដែលត្រូវបានអនុវត្តស្របតាមបទប្បញ្ញត្តិនៃមាត្រា VI នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ កិច្ចព្រមព្រៀងស្តីពីការអនុវត្តមាត្រា

VI នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មឆ្នាំ១៩៩៤ នៅក្នុងឧបសម្ព័ន្ធ 1A នៃកិច្ចព្រមព្រៀង WTO ដែលអាចនឹងត្រូវបានធ្វើវិសោធនកម្មនិងកិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធន និងវិធានការពន្ធប៉ះប៉ូវនៅក្នុងឧបសម្ព័ន្ធ1A នៃកិច្ចព្រមព្រៀង WTO ដែលអាចនឹងត្រូវបានធ្វើវិសោធនកម្ម ឬ

(iii) កម្រៃឬការគិតថ្លៃ កំណត់ដោយមាត្រា VIII នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤

ជ) **កិច្ចព្រមព្រៀងការកំណត់តម្លៃគិតពន្ធគយ** មានន័យថា កិច្ចព្រមព្រៀងស្តីពីការអនុវត្តមាត្រា VII នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្មឆ្នាំ១៩៩៤ នៅក្នុងឧបសម្ព័ន្ធ1A នៃកិច្ចព្រមព្រៀង WTO។

ឈ) **ថ្ងៃ** មានន័យថា ថ្ងៃប្រតិទិន រាប់បញ្ចូលទាំងថ្ងៃចុងសប្តាហ៍និងថ្ងៃឈប់សម្រាកផងដែរ។

ញ) GATS មានន័យថា កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម នៅក្នុងឧបសម្ព័ន្ធ1B នៃកិច្ចព្រមព្រៀង WTO។

ដ) GATT **ឆ្នាំ១៩៩៤** មានន័យថា កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្មឆ្នាំ១៩៩៤ នៅក្នុងឧបសម្ព័ន្ធ1A នៃកិច្ចព្រមព្រៀង WTO។

ឋ) **ប្រព័ន្ធសុខដុមនីយកម្ម ឬ HS Code ឬ HS** មានន័យថា ប្រព័ន្ធសុខដុមនីយកម្មសម្រាប់បរិយាយមុខទំនិញ ដែលត្រូវបានបង្កើតឡើងដោយអនុសញ្ញាអន្តរជាតិស្តីពីប្រព័ន្ធកូដនិងបរិយាយមុខទំនិញអន្តរជាតិ ដែលត្រូវបានចុះហត្ថលេខានៅទីក្រុងព្រុចសែល ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៨៣។

ឌ) **ការផ្តល់អាជ្ញាបណ្ណនាំចូល** មានន័យថា នីតិវិធីរដ្ឋបាលដែលតម្រូវឱ្យដាក់ពាក្យស្នើសុំ ឬឯកសារផ្សេងៗទៀត(ក្រៅពីឯកសារដែលត្រូវបានតម្រូវសម្រាប់គោលបំណងពន្ធគយ)ទៅអង្គភាពរដ្ឋបាលពាក់ព័ន្ធជាលក្ខខណ្ឌបឋមសម្រាប់ការនាំចូលទំនិញចូលក្នុងតំបន់របស់ភាគីដែលនាំចូល។

ឍ) **រដ្ឋសមាជិកអាស៊ានថ្មី** មានន័យថា ប្រទេសកម្ពុជា ប្រទេសឡាវ ប្រទេសមីយ៉ាន់ម៉ា និងប្រទេសវៀតណាម។

ណ) **ទំនិញដើមកំណើត** មានន័យថា ទំនិញដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ជាប្រភពដើមក្រោមជំពូក៣ (វិធានដើមកំណើត) ។

ត) **បណ្តាភាគី** មានន័យថា ហុងកុង នៃប្រទេសចិននិងបណ្តារដ្ឋសមាជិកអាស៊ាន ដែលជាភាគីនៃកិច្ចព្រមព្រៀង ដែលបានចូលជាធរមាននេះ។

ថ) **ភាគី** មានន័យថា ហុងកុង នៃប្រទេសចិន ឬរដ្ឋសមាជិកអាស៊ានណាមួយដែលជាភាគីនៃកិច្ចព្រមព្រៀង ដែលបានចូលជាធរមាននេះ។

ទ) **កិច្ចព្រមព្រៀង SPS** មានន័យថា កិច្ចព្រមព្រៀងស្តីពីការអនុវត្តវិធានការអនាម័យនិងភូតគាមអនាម័យនៅក្នុងឧបសម្ព័ន្ធ1A នៃកិច្ចព្រមព្រៀង WTO។

ធ) WTO មានន័យថា អង្គការពាណិជ្ជកម្មពិភពលោក។

ន) **កិច្ចព្រមព្រៀង WTO** មានន័យថា កិច្ចព្រមព្រៀង Marrakesh ដែលបង្កើតអង្គការពាណិជ្ជកម្មពិភពលោក នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៤ និង

ប) **ការយល់ដឹងអំពីការដោះស្រាយវិវាទរបស់ WTO** មានន័យថា ការយល់ដឹងអំពីវិធាននិងនីតិវិធីក្នុងការគ្រប់គ្រងការដោះស្រាយវិវាទក្នុងឧបសម្ព័ន្ធ២ នៃកិច្ចព្រមព្រៀងWTO។

## មាត្រា៥

## ការបកស្រាយ

នៅក្នុងកិច្ចព្រមព្រៀងនេះ លើកលែងតែបរិបទតម្រូវៈ

ក- ក្នុងករណីក្រុងហុងកុង នៃប្រទេសចិន ឃ្លាដែលត្រូវបានបញ្ជាក់អត្ថន័យជាពាក្យថា "ជាតិ" ឃ្លានេះត្រូវបកស្រាយថាពាក់ព័ន្ធនឹងក្រុងហុងកុង នៃប្រទេសចិន។

ខ- ចំពោះហុងកុង នៃប្រទេសចិន ការយោងទៅលើកិច្ចព្រមព្រៀងអន្តរជាតិដែលភាគីណាមួយជាហត្ថលេខី ត្រូវរួមបញ្ចូលកិច្ចព្រមព្រៀងអន្តរជាតិមួយដែលអាចអនុវត្តបាន ចំពោះក្រុងហុងកុង នៃប្រទេសចិននិងការយោងណាមួយទៅលើសិទ្ធិ កាតព្វកិច្ច ឬកិច្ចការរបស់ភាគីមួយក្រោមកិច្ចព្រមព្រៀង ឬការរៀបចំអន្តរជាតិ ត្រូវរួមបញ្ចូលសិទ្ធិ កាតព្វកិច្ច ឬការទទួលខុសត្រូវដែលអាចអនុវត្តបាន ចំពោះក្រុងហុងកុង នៃប្រទេសចិន ក្រោមកិច្ចព្រមព្រៀងអន្តរជាតិបែបនេះ និង

គ- អ្វីៗទាំងអស់នៅក្រោមកិច្ចព្រមព្រៀងនេះត្រូវធ្វើឡើងក្នុងអំឡុងពេលប៉ុន្មានថ្ងៃចាប់ពី ក្រោយ មុន ឬនៅកាលបរិច្ឆេទជាក់លាក់ណាមួយ ដែលកាលបរិច្ឆេទជាក់លាក់ ឬនៅកាលបរិច្ឆេទដែលព្រឹត្តិការណ៍ជាក់លាក់កើតឡើង មិនត្រូវរាប់បញ្ចូលនៅក្នុងការគណនាចំនួនថ្ងៃនោះទេ។

# ជំពូក២

# ពាណិជ្ជកម្មទំនិញ

## មាត្រា១

## វិសាលភាព

លើកលែងតែមានការចែងផ្សេង ជំពូកនេះនឹងត្រូវអនុវត្តចំពោះការធ្វើពាណិជ្ជកម្មសម្រាប់ទំនិញទាំងអស់ក្នុងចំណោមបណ្តាភាគី។

## មាត្រា២

## ការកាត់បន្ថយ និង/ឬ ការលុបបំបាត់ពន្ធគយ

លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗត្រូវកាត់បន្ថយ និង/ឬ លុបបំបាត់ពន្ធគយជាបន្តបន្ទាប់លើទំនិញដែលមានដើមកំណើតរបស់បណ្តាភាគីផ្សេងទៀត ដោយអនុលោមតាមតារាងការសន្យាពន្ធគយរបស់ខ្លួនក្នុងឧបសម្ព័ន្ធ ២-១ (តារាងកម្មវិធីពន្ធគយ)។

**មាត្រា៣**

**ការមិនផ្លាស់ប្តូរ**

លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ ពុំមានភាគីណាមួយអាចបង្កើនតម្លៃពន្ធគយលើទំនិញដែលមានដើមកំណើតរបស់ភាគីផ្សេងទៀត ដែលមិនស្របទៅតាមតារាងការសន្យាពន្ធគយក្នុងឧបសម្ព័ន្ធ ២-១ (តារាងកម្មវិធីពន្ធគយ)។

**មាត្រា៤**

**ការពន្លឿនការសន្យា**

ពុំមានប្រការណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ អាចទប់ស្កាត់បណ្តាភាគីពីការចរចានិងការចូលរួមក្នុងកិច្ចរៀបចំនានា ដើម្បីពន្លឿននូវការអនុវត្តការសន្យាដែលធ្វើឡើងនៅក្រោមកិច្ចព្រមព្រៀងនេះឡើយ ប្រសិនបើកិច្ចរៀបចំទាំងនោះត្រូវបានឯកភាពគ្នាទៅវិញទៅមកនិងអនុវត្តដោយបណ្តាភាគីទាំងអស់។

**មាត្រា៥**

**ប្រព្រឹត្តកម្មជាតិស្តីពីពន្ធដារ និងបទប្បញ្ញត្តិក្នុងស្រុក**

ភាគីនីមួយៗត្រូវផ្តល់ប្រព្រឹត្តកម្មជាតិចំពោះទំនិញរបស់បណ្តាភាគីផ្សេងទៀត ដោយអនុលោមទៅតាមមាត្រា III នៃ GATT ឆ្នាំ១៩៩៤។ ក្នុងន័យនេះ មាត្រា III នៃ GATT ឆ្នាំ១៩៩៤ ត្រូវបញ្ចូលនិងបង្កើតជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ *ហើយត្រូវយកមកអនុវត្តដូចគ្នា។*

**មាត្រា៦**

**កម្រៃ និងថ្លៃសេវាទាក់ទងនឹងការនាំចូល និងការនាំចេញ**

១- ភាគីនីមួយៗត្រូវធានាថា កម្រៃនិងថ្លៃសេវាទាក់ទងនឹងការនាំចូលនិងការនាំចេញ ត្រូវស្របទៅតាមសិទ្ធិនិងកាតព្វកិច្ច ក្រោមមាត្រា VIII របស់ GATT ឆ្នាំ១៩៩៤។

២- ភាគីនីមួយៗត្រូវធ្វើយ៉ាងណាឱ្យព័ត៌មានលម្អិតទាក់ទងទៅនឹងកម្រៃនិងថ្លៃសេវាដែលត្រូវបង់ចំពោះការនាំចូលនិងការនាំចេញអាចស្វែងរកបាន និងតាមដែលអាចធ្វើទៅបាន ហើយអនុលោមតាមច្បាប់ក្នុងស្រុករបស់ខ្លួន ត្រូវដាក់ព័ត៌មានទាំងនោះនៅលើបណ្តាញអ៊ីនធឺណែត។

៣- ភាគីនីមួយៗមិនតម្រូវឱ្យបញ្ជាក់ពីច្បាប់ និងផ្ទៀងផ្ទាត់ឯកសារពន្ធគយពាក់ព័ន្ធនឹងកម្រៃនិងថ្លៃសេវាទាក់ទងនឹងការនាំចូលទំនិញណាមួយ ពីភាគីដទៃណាមួយឡើយ។

**មាត្រា៧**

**វិធានការការពារតុល្យភាពនៃការទូទាត់**

ពុំមានប្រការណាមួយនៅក្នុងជំពូកនេះត្រូវបានបកស្រាយ ដើម្បីទប់ស្កាត់ភាគីមួយពីការចាត់វិធានការទាំងឡាយណាក្នុងគោលបំណងការពារតុល្យភាពនៃការទូទាត់ ដោយអនុលោមតាមមាត្រា XII នៃ GATT



V

ឆ្នាំ១៩៩៤ និងបទប្បញ្ញត្តិស្តីពីការយល់ដឹងពីតុល្យភាពនៃការទូទាត់ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មឆ្នាំ១៩៩៤ ក្នុងឧបសម្ព័ន្ធ1A នៃកិច្ចព្រមព្រៀង WTO ។

## មាត្រា៨

## ការផ្សព្វផ្សាយ និងការរៀបចំបទប្បញ្ញត្តិពាណិជ្ជកម្ម

១- មាត្រា X នៃ GATT ឆ្នាំ១៩៩៤ ត្រូវបានបញ្ចូលនិងត្រូវបង្កើតជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ *ហើយត្រូវយកមកអនុវត្តដូចគ្នា។*

២- ដោយអនុលោមតាមច្បាប់ក្នុងស្រុករបស់ខ្លួននិងតាមដែលអាចធ្វើទៅបាន ភាគីនីមួយៗត្រូវធ្វើយ៉ាងណាឱ្យច្បាប់ បទប្បញ្ញត្តិ សេចក្តីសម្រេច និងវិធាននានា ដូចមានចែងក្នុងកថាខណ្ឌ១ មាននៅលើបណ្តាញអ៊ីនធឺណែត។

## មាត្រា៩

## ការដាក់កម្រិតលើបរិមាណនិងវិធានការមិនមែនពន្ធគយ

១- ពុំមានភាគីណាមួយត្រូវអនុម័ត ឬរក្សាទុករាល់ការហាមឃាត់ ឬការដាក់កម្រិតលើបរិមាណចំពោះការនាំចូលទំនិញពីភាគីផ្សេងឬចំពោះការនាំចេញទំនិញទៅកាន់ដែនដីនៃភាគីផ្សេងឡើយ លើកលែងតែអនុលោមទៅតាមសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនក្រោមWTO ឬអនុលោមតាមកិច្ចព្រមព្រៀងនេះ។ ក្នុងន័យនេះ មាត្រា XI នៃ GATT ឆ្នាំ១៩៩៤ ត្រូវបញ្ចូលនិងបង្កើតជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ *ហើយត្រូវយកមកអនុវត្តដូចគ្នា។*

២- លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ ភាគីមួយមិនត្រូវអនុម័ត ឬរក្សាទុកវិធានការមិនមែនពន្ធគយទាំងឡាយណាចំពោះការនាំចូលទំនិញណាមួយពីភាគីផ្សេង ឬចំពោះការនាំចេញទំនិញណាមួយទៅកាន់ដែនដីរបស់ភាគីផ្សេងទៀត លើកលែងតែអនុលោមទៅតាមសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនក្រោម WTO ។

៣- ភាគីនីមួយៗត្រូវធានានូវតម្លាភាពនៃវិធានការមិនមែនពន្ធគយរបស់ខ្លួន ដែលអនុញ្ញាតក្រោមកថាខណ្ឌ២ និងត្រូវធានាថាវិធានការទាំងនោះមិនត្រូវបានរៀបចំ អនុម័ត ឬអនុវត្ត ដោយគោលបំណង ឬដោយឥទ្ធិពល ដែលបង្កើតឱ្យមានឧបសគ្គមិនចាំបាច់ក្នុងការធ្វើពាណិជ្ជកម្មក្នុងចំណោមបណ្តាភាគី។

## មាត្រា១០

## ការផ្តល់អាជ្ញាបណ្ណនាំចូល

១- ភាគីនីមួយៗត្រូវធានាថា រាល់វិធានការនៃការផ្តល់អាជ្ញាបណ្ណនាំចូលស្វ័យប្រវត្តនិងមិនស្វ័យប្រវត្តត្រូវបានអនុវត្តដោយតម្លាភាពនិងអាចប៉ាន់ស្មានបានហើយអនុវត្តដោយអនុលោមតាម*កិច្ចព្រមព្រៀងស្តីពីនីតិវិធីផ្តល់អាជ្ញាបណ្ណនាំចូល* ក្នុងឧបសម្ព័ន្ធ1A នៃកិច្ចព្រមព្រៀង WTO។

២- នៅពេលដែលមានការស្នើសុំពីភាគីផ្សេង ភាគីមួយត្រូវឆ្លើយតបឱ្យបានលឿនចំពោះការស្នើសុំរបស់ភាគីនោះតាមដែលអាចធ្វើទៅបាន សម្រាប់រាល់ព័ត៌មានស្ដីពីតម្រូវការអាជ្ញាបណ្ណនាំចូលតាមបែបបទទូទៅ។

## មាត្រា១១

## ការកែប្រែសម្បទាន

១- ភាគីនីមួយៗ មិនត្រូវទុកជាមោឃៈឬបន្ថយរាល់សម្បទានរបស់ខ្លួនដែលស្ថិតក្រោមកិច្ចព្រមព្រៀងនេះឡើយ លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ។

២- ក្នុងកាលៈទេសៈលើកលែង ករណីដែលភាគីមួយប្រឈមនឹងការលំបាកជាយថាហេតុក្នុងការអនុវត្តនូវការសន្យាពន្ធគយរបស់ខ្លួន ភាគីនោះអាចកែប្រែឬដកចេញនូវសម្បទានរបស់ខ្លួនដែលមាននៅក្នុងតារាងកម្មវិធីពន្ធគយក្នុងឧបសម្ព័ន្ធ២-១ (តារាងកម្មវិធីពន្ធគយ) តាមរយៈការចរចានិងការព្រមព្រៀងគ្នាជាមួយនឹងភាគីទាំងឡាយដែលខ្លួនបានផ្ដល់សម្បទាន ក្រោមកិច្ចព្រមព្រៀងនេះ។ ចំពោះការចរចានិងការព្រមព្រៀងគ្នាបែបនោះ ដែលនៅក្នុងនោះអាចរួមមានទាំងការទូទាត់សំណងសមរម្យទាក់ទងនឹងទំនិញផ្សេងទៀតផងដែរ បណ្ដាភាគីពាក់ព័ន្ធត្រូវរក្សានូវកម្រិតទូទៅនៃសម្បទានដែលមានអត្ថប្រយោជន៍ទៅវិញទៅមកមិនឱ្យតិចជាងភាពអនុគ្រោះពាណិជ្ជកម្ម ដែលផ្ដល់ដល់កិច្ចព្រមព្រៀងនេះនៅមុនការចរចាទាំងនោះឡើយ។

## មាត្រា១២

## ការិយាល័យទំនាក់ទំនងនិងការពិគ្រោះយោបល់

១- ភាគីនីមួយៗត្រូវចាត់តាំងការិយាល័យទំនាក់ទំនងមួយ ដើម្បីសម្របសម្រួលដល់ទំនាក់ទំនងក្នុងចំណោមបណ្ដាភាគីចំពោះបញ្ហាទាំងឡាយពាក់ព័ន្ធនឹងជំពូកនេះ។ ភាគីនីមួយៗត្រូវជូនដំណឹងដល់បណ្ដាភាគីផ្សេងទៀតឱ្យបានឆាប់អំពីការកែប្រែព័ត៌មានលម្អិតនៃការិយាល័យទំនាក់ទំនងរបស់ខ្លួន។

២- នៅពេលដែលភាគីមួយយល់ថា វិធានការដែលស្នើឡើងឬវិធានការជាក់ស្ដែងរបស់ភាគីផ្សេងទៀតឬបណ្ដាភាគីផ្សេងទៀត អាចជះឥទ្ធិពលគួរឱ្យកត់សម្គាល់ចំពោះពាណិជ្ជកម្មទំនិញក្នុងចំណោមបណ្ដាភាគី ភាគីនោះអាចស្នើសុំព័ត៌មានលម្អិត ដែលពាក់ព័ន្ធទៅនឹងវិធានការនោះតាមរយៈការិយាល័យទំនាក់ទំនងនិងករណីចាំបាច់អាចស្នើសុំពិគ្រោះយោបល់ ក្នុងគោលបំណងដោះស្រាយនូវរាល់កង្វល់អំពីវិធានការនោះ។ ភាគីឬបណ្ដាភាគីដែលត្រូវបានស្នើសុំ ត្រូវឆ្លើយតបឱ្យបានឆាប់ទៅនឹងការស្នើសុំព័ត៌មានឬការពិគ្រោះយោបល់ទាំងនោះ។

៣- សកម្មភាពទាំងឡាយដែលអនុលោមតាមកថាខណ្ឌ២ ពុំត្រូវធ្វើឡើងឱ្យប៉ះពាល់ដល់សិទ្ធិនិងកាតព្វកិច្ចរបស់បណ្ដាភាគីក្រោមជំពូក១៣(ការពិគ្រោះយោបល់និងការដោះស្រាយវិវាទ) ឬក្រោមការយល់ដឹងអំពីការដោះស្រាយវិវាទរបស់ WTO ឡើយ។

## ឧបសម្ព័ន្ធ២-១

## តារាងកម្មវិធីពន្ធគយ

## ផ្នែកទី១

## កំណត់សម្គាល់ទូទៅ

១- ឧបសម្ព័ន្ធនេះផ្អែកលើប្រព័ន្ធសុខដុមនីយកម្មដូចបានធ្វើវិសោធនកម្មនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១២។

២- អត្រាពន្ធគយគោលសម្រាប់ការកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយ ត្រូវអនុវត្តតាមអត្រាពន្ធគយក្រោមគោលការណ៍ប្រជាជាតិ ដែលទទួលបានភាពអនុគ្រោះបំផុត (MFN) ដែលមានសុពលភាពកាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ លើកលែងតែប្រទេសឥណ្ឌូណេស៊ី ដែលអត្រាពន្ធគោលត្រូវអនុវត្តតាមអត្រាពន្ធ MFN ដែលមានសុពលភាពកាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦។

៣- បន្ទាត់ពន្ធគយដែលអាស្រ័យទៅនឹងការកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយ ដែលស្ថិតក្រោមឧបសម្ព័ន្ធនេះត្រូវចាត់ថ្នាក់ដោយផ្អែកលើម៉ូដែលខាងក្រោម៖

| ប្រភេទ | | អត្រាពន្ធចុងក្រោយ | អាស៊ាន ៦ | | | | កម្ពុជា / ឡាវ /មីយ៉ាន់ម៉ា | |
|---|---|---|---|---|---|---|---|---|
| | | | ព្រុយណេ/ម៉ាឡេស៊ី / ហ្វីលីពីន / ថៃ | | ឥណ្ឌូណេស៊ី /វៀតណាម | | | |
| **បញ្ជីធម្មតា** | បញ្ជីធម្មតាទី១ | ០% | ៨៥% | ៦៥% ក្នុងអំឡុងពេល ៣ឆ្នាំ | ៧៥% | ៥០% ក្នុងអំឡុងពេល ៣ឆ្នាំ | ៦៥% | ៥០% ក្នុងអំឡុងពេល ៨ឆ្នាំ |
| | បញ្ជីធម្មតាទី២ | ០% | | ២០% ក្នុងអំឡុងពេល ១០ឆ្នាំ | | ២៥% ក្នុងអំឡុងពេល ១០ឆ្នាំ | | ១៥% ក្នុងអំឡុងពេល ១៥ឆ្នាំ |
| **បញ្ជីវេទយិត** | បញ្ជីវេទយិត | ០-៥% | ១០% | ៥% ក្នុងអំឡុងពេល ១២ឆ្នាំ | ១០% | ៥% ក្នុងអំឡុងពេល ១២ឆ្នាំ | ២០% | ១០% ក្នុងអំឡុងពេល ១៧ឆ្នាំ |
| | បញ្ជីវេទយិតខ្ពស់ | ≤៥០% | | ៥% ក្នុងអំឡុងពេល ១៤ឆ្នាំ | | ៥% ក្នុងអំឡុងពេល ១៤ឆ្នាំ | | ១០% ក្នុងអំឡុងពេល ២០ឆ្នាំ |
| **បញ្ជីលើកលែង** | | មិនមានការសន្យាពន្ធគយ | ៥% | | ១៥% | | ១៥% | |

៤- សម្រាប់គោលបំណងនៃឧបសម្ព័ន្ធនេះ ពាក្យថា"កាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន" មានន័យថា កាលបរិច្ឆេទនៃការចូលជាធរមានរបស់កិច្ចព្រមព្រៀងនេះ ដោយអនុលោមតាមកថាខណ្ឌ ១ ឬ២ នៃមាត្រា៤ (ការចូលជាធរមាន) នៃជំពូក១៤ (អវសានប្បញ្ញត្តិ) ដែលក្នុងចំណោមកថាខណ្ឌទាំងពីរនេះអាចអនុវត្តមួយណាក៏បាន។

៥- សម្រាប់ភាគីដែលកិច្ចព្រមព្រៀងនេះចូលជាធរមាននៅក្រោយកាលបរិច្ឆេទ ដោយអនុលោមតាមកថាខណ្ឌ៣ នៃមាត្រា៤ (ការចូលជាធរមាន) នៃជំពូក១៤ (អវសានប្បញ្ញត្តិ) នោះការកាត់បន្ថយ ឬការលុបបំបាត់ពន្ធគយលើកដំបូងត្រូវអនុវត្តនៅក្នុងកម្រិត ដូចបានកំណត់ក្នុងតារាងកម្មវិធីពន្ធគយរបស់ភាគីនោះ នៅក្នុងឆ្នាំដែលកិច្ចព្រមព្រៀងនេះចូលជាធរមានសម្រាប់ភាគីនោះ។

៦- ក្នុងករណីពន្ធគិតតាមតម្លៃ (ad valorem) អត្រាពន្ធដែលជាលទ្ធផលពីកម្មវិធីកាត់បន្ថយពន្ធគយគួរបញ្ជាក់ជាតួលេខទាំងស្រុង។ ចំនួនទសភាគទាំងឡាយណា ដែលតិចជាង០,៥ នៃចំនួនជាភាគរយត្រូវបង្គត់ចុះ ហើយចំនួនទសភាគទាំងឡាយណាដែលធំជាង០,៥ នៃចំនួនជាភាគរយត្រូវបង្គត់ឡើង។ ក្នុងករណីពន្ធជាក់លាក់ ចំនួនទសភាគទាំងឡាយណាដែលតិចជាង០,០១ នៃឯកតារូបិយវត្ថុផ្លូវការរបស់ភាគីមួយ ត្រូវបង្គត់ទៅឱ្យជិតដល់ខ្ទង់ទី២ (សម្រាប់ចំនួនទសភាគដែលស្មើ ឬធំជាង០,០០៥ ត្រូវបង្គត់ទៅ០,០១)។

### ម៉ូដែលសម្រាប់ផលិតផលក្នុងបញ្ជីធម្មតា

៧- បណ្តាភាគីទាំងអស់គួរចាត់ថ្នាក់បន្ទាត់ពន្ធគយ ដែលពួកគេបានសន្យាក្រោមបញ្ជីធម្មតាទៅជាបញ្ជីធម្មតាទី១និងបញ្ជីធម្មតាទី២ហើយត្រូវកាត់បន្ថយនិងលុបបំបាត់បន្ទាត់ពន្ធគយ ដែលអនុវត្តអត្រាពន្ធគយ MFN លើបន្ទាត់ពន្ធគយទាំងនោះដោយយោងតាមម៉ូដែលដូចខាងក្រោម៖

(ក) បញ្ជីធម្មតាទី១៖ លើកលែងតែមានចែងក្នុងវាក្យខណ្ឌ៨ (ខ) បន្ទាត់ពន្ធគយ ដែលអនុវត្តអត្រាពន្ធគយ MFN ត្រូវកាត់បន្ថយដោយសមាមាត្រស្មើគ្នាទៅនឹង០% ក្នុងរយៈពេលបីឆ្នាំសម្រាប់រដ្ឋសមាជិកអាស៊ាន៦និងរយៈពេលប្រាំបីឆ្នាំសម្រាប់កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។

(i) ការកាត់បន្ថយលើកទី១ ត្រូវធ្វើឡើងនៅកាលបរិច្ឆេទ ដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន និង

(ii) ការកាត់បន្ថយបន្តបន្ទាប់ត្រូវធ្វើឡើងនៅថ្ងៃទី០១ ខែមករា នៃឆ្នាំបន្តបន្ទាប់

(ខ) បញ្ជីធម្មតាទី២៖ លើកលែងតែមានចែងក្នុងវាក្យខណ្ឌ៨ (ខ) បន្ទាត់ពន្ធគយ ដែលអនុវត្តអត្រាពន្ធគយ MFN ត្រូវកាត់បន្ថយរៀងរាល់ពីរឆ្នាំម្តង ដោយសមាមាត្រស្មើគ្នាទៅនឹង 0% ក្នុងរយៈពេលដប់ឆ្នាំសម្រាប់រដ្ឋសមាជិកអាស៊ាន៦ និងរយៈពេលដប់ប្រាំឆ្នាំសម្រាប់កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។

(i) ការកាត់បន្ថយលើកទី១ ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន និង

(ii) ការកាត់បន្ថយបន្តបន្ទាប់ត្រូវធ្វើឡើងនៅថ្ងៃទី០១ ខែមករា រៀងរាល់ពីរឆ្នាំម្តងនៃឆ្នាំបន្តបន្ទាប់

៨- សម្រាប់គោលបំណងនៃការអនុវត្តការកាត់បន្ថយពន្ធគយក្រោមបញ្ជីធម្មតាទី១និងបញ្ជីធម្មតាទី២ ត្រូវអនុវត្តដូចខាងក្រោម៖

(ក) អត្រាពន្ធលើស៥% ត្រូវកាត់បន្ថយដោយសមាមាត្រស្មើគ្នា និង

(ខ) អត្រាពន្ធតិចជាង ឬស្មើ ៥% ត្រូវបន្ថយមកត្រឹម០% យ៉ាងយូរបំផុតក្នុងអំឡុងពេលនៃការកាត់បន្ថយពន្ធគយ។

**ម៉ូដែលសម្រាប់ផលិតផលក្នុងបញ្ជីរសេយិត**

៩- បញ្ជីរសេយិត៖ បណ្តាភាគីត្រូវកាត់បន្ថយនិងបើអាចធ្វើទៅបានលុបបំបាត់ពន្ធគយដែលអនុវត្តអត្រាពន្ធគយ MFN នៃបន្ទាត់ពន្ធគយមាននៅក្នុងបញ្ជីរសេយិតដោយផ្អែកតាមម៉ូដែលដូចខាងក្រោម៖

(ក) រដ្ឋសមាជិកអាស៊ាន៦ ត្រូវកាត់បន្ថយការអនុវត្តអត្រាពន្ធគយ MFN នៃបន្ទាត់ពន្ធគយដែលមានក្នុងបញ្ជីរសេយិតពី០-៥% ក្នុងរយៈពេល ១២ឆ្នាំ នៃកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន: ការកាត់បន្ថយអត្រាពន្ធគយទាំងនេះ ត្រូវចាប់ផ្តើមពីថ្ងៃទី០១ ខែមករា នៃឆ្នាំទីប្រាំមួយ ហើយជាបន្តបន្ទាប់ អត្រាពន្ធគយត្រូវកាត់បន្ថយពី០-៥% យ៉ាងយូរត្រឹមឆ្នាំទីដប់ពីរ លុះត្រាតែមានបញ្ជាក់ក្នុងតារាងសន្យារបស់បណ្តាភាគីដែលបានឯកភាពជាមួយហុងកុង នៃប្រទេសចិន។

(ខ) កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ត្រូវកាត់បន្ថយពន្ធគយដែលអនុវត្តអត្រាពន្ធគយ MFN នៃបន្ទាត់ពន្ធគយដែលមានក្នុងបញ្ជីរសេយិតពី០-៥% ក្នុងរយៈពេល១៧ឆ្នាំ នៃកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន។ ការកាត់បន្ថយអត្រាពន្ធគយទាំងនេះ គួរចាប់ផ្តើមពីថ្ងៃទី០១ ខែមករា នៃឆ្នាំទីប្រាំបួន ហើយជាបន្តបន្ទាប់ អត្រាពន្ធគយត្រូវកាត់បន្ថយពី០-៥% នៅចុងក្រោយបង្អស់នៅក្នុងឆ្នាំទីដប់ប្រាំពីរ លុះត្រាតែមានបញ្ជាក់ក្នុងតារាងសន្យារបស់បណ្តាភាគីដែលបានឯកភាពជាមួយហុងកុង នៃប្រទេសចិន។

១០- បញ្ជីរសេយិតខ្ពស់៖ បណ្តាភាគីត្រូវកាត់បន្ថយនិងបើអាចធ្វើទៅបាន លុបបំបាត់អត្រាពន្ធគយ MFN នៃបន្ទាត់ពន្ធដែលមានក្នុងបញ្ជីរសេយិតខ្ពស់ ដោយផ្អែកតាមម៉ូដែលដូចខាងក្រោម៖

(ក) រដ្ឋសមាជិកអាស៊ាន៦ ត្រូវកាត់បន្ថយអត្រាពន្ធគយ MFN នៃបន្ទាត់ពន្ធដែលមានក្នុងបញ្ជីរសេយិតខ្ពស់របស់ខ្លួនមិនឱ្យលើសពី៥០% ក្នុងរយៈពេល១៤ឆ្នាំ នៃកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន។

(ខ) កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ត្រូវកាត់បន្ថយអត្រាពន្ធគយ MFN នៃបន្ទាត់ពន្ធដែលមានក្នុងបញ្ជីរសេយិតខ្ពស់របស់ខ្លួនមិនឱ្យលើសពី៥០% ក្នុងរយៈពេល២០ឆ្នាំ នៃកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន។



ﾚ

(គ) ការកាត់បន្ថយមិនត្រូវអនុវត្តចំពោះអត្រាពន្ធគយដែលមានកម្រិតស្មើឬតិចជាង៥០% គិតត្រឹមកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះចូលជាធរមានឡើយ។

១១- ទោះបីជាយ៉ាងណាក៏ដោយ៖

(ក) ហុងកុង នៃប្រទេសចិន ត្រូវលុបបំបាត់ពន្ធគយលើទំនិញមានដើមកំណើតនៃភាគីផ្សេងទៀតដោយគ្រប់ដណ្តប់លើទំនិញទាំងអស់ដែលមានចែងក្នុងប្រព័ន្ធសុខដុមនីយកម្មជំពូក១ ដល់ ៩៧ ដោយគិតចាប់ពីកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន និង

(ខ) សិង្ហបុរី ត្រូវលុបបំបាត់ពន្ធគយលើរាល់ទំនិញមានដើមកំណើតនៃភាគីផ្សេងទៀតក្រោមកិច្ចព្រមព្រៀងនេះ ដោយគិតចាប់ពីកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះចូលជាធរមានសម្រាប់សិង្ហបុរី។

ផ្នែកទី២ តារាងកម្មវិធីរបស់ព្រុយណេ

ផ្នែកទី៣ តារាងកម្មវិធីរបស់កម្ពុជា

ផ្នែកទី៤ តារាងកម្មវិធីរបស់ឥណ្ឌូណេស៊ី

ផ្នែកទី៥ តារាងកម្មវិធីរបស់ឡាវ

ផ្នែកទី៦ តារាងកម្មវិធីរបស់ម៉ាឡេស៊ី

ផ្នែកទី៧ តារាងកម្មវិធីរបស់មីយ៉ាន់ម៉ា

ផ្នែកទី៨ តារាងកម្មវិធីរបស់ហ្វីលីពីន

ផ្នែកទី៩ តារាងកម្មវិធីរបស់សិង្ហបុរី

ផ្នែកទី១០ តារាងកម្មវិធីរបស់ថៃ

ផ្នែកទី១១ តារាងកម្មវិធីរបស់វៀតណាម

ផ្នែកទី១២ តារាងកម្មវិធីរបស់ហុងកុង ប្រទេសចិន

# ជំពូក៣

# វិធានដើមកំណើត

## មាត្រា១

## លក្ខខណ្ឌទទួលបានប្រព្រឹត្តកម្មពន្ធអនុគ្រោះ

ក្នុងការកំណត់ដើមកំណើតនៃទំនិញ ដែលអាចទទួលបានប្រព្រឹត្តកម្មពន្ធអនុគ្រោះ ដោយយោងតាមជំពូក២ (ពាណិជ្ជកម្មទំនិញ) នៃកិច្ចព្រមព្រៀងនេះ បទប្បញ្ញត្តិទាំងឡាយក្នុងជំពូកនេះត្រូវអនុវត្ត។

## មាត្រា២

## និយមន័យ

សម្រាប់គោលបំណងនៃជំពូកនេះ៖

ក) **វារីវប្បកម្ម** មានន័យថា ការធ្វើកសិកម្មនៃសរីរាង្គរស់នៅក្នុងទឹក រួមមានត្រី សិប្បីសត្វ សត្វមានសម្បក និបិដ្យាដ្ឋិកសត្វដែលឥតឆ្អឹងខ្នងនិងរុក្ខជាតិដុះក្នុងទឹកផ្សេងទៀត ចេញពីការបម្រាញ់ពូជ ដូចជាស៊ុត កូនត្រីទើបញាស់ កូនត្រី និងកូនញាស់ដោយធ្វើអន្តរាគមន៍ក្នុងដំណើរការចិញ្ចឹម ឬលូតលាស់ដើម្បីបង្កើនផលិតកម្មដូចជាការស្តុកទុក ការចិញ្ចឹម ឬការការពារពីសត្វស៊ីសាច់ជាទូទៅ។

ខ) **ថ្លៃទំនិញ បូកថ្លៃធានារ៉ាប់រង បូកថ្លៃដឹកជញ្ជូន** (CIF) មានន័យថា ជាថ្លៃនៃទំនិញដែលបាននាំចូល ហើយរួមបញ្ចូលទាំងថ្លៃដឹកជញ្ជូននិងការធានារ៉ាប់រងដល់កំពង់ផែ ឬទីកន្លែងនៃច្រកចូលទៅកាន់ភាគីនាំចូល។

គ) **ថ្លៃទំនិញដឹកជញ្ជូនមកដល់លើនាវា** (FOB) មានន័យថា ជាតម្លៃទំនិញដែលដឹកជញ្ជូនមកដល់លើនាវារួមទាំងចំណាយនៃការដឹកជញ្ជូនទំនិញទៅកាន់កំពង់ផែឬទីកន្លែងដឹកជញ្ជូនចុងក្រោយបំផុតនៅក្រៅប្រទេស។

ឃ) **គោលការណ៍គណនេយ្យទទួលស្គាល់ទូទៅ** (GAAP) មានន័យថា ការព្រមព្រៀងគ្នាជារួមដែលត្រូវបានទទួលស្គាល់ ឬមានការគាំទ្រពីអាជ្ញាធរនៅក្នុងភាគី ពាក់ព័ន្ធនឹងការកត់ត្រាចំណូល ចំណាយ ថ្លៃដើម ទ្រព្យសកម្មនិងបំណុល ការលាតត្រដាងព័ត៌មាននិងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ ស្តង់ដាទាំងនេះអាចរួមបញ្ចូលទាំងគោលការណ៍ណែនាំទូលំទូលាយនៃកម្មវិធីទូទៅ រួមទាំងស្តង់ដាលម្អិត ការអនុវត្តនិងនីតិវិធីផ្សេងៗ។

ង) **ទំនិញ** មានន័យថា ជាវត្ថុធាតុឬផលិតផល ដែលអាចទទួលបានទាំងស្រុងឬត្រូវបានផលិតឡើងទាំងស្រុង ទោះបីជាវាត្រូវបានបម្រុងទុកសម្រាប់ការប្រើប្រាស់លើកក្រោយជាវត្ថុធាតុនៅក្នុងដំណើរការផលិតកម្មផ្សេងទៀតក៏ដោយ។ សម្រាប់គោលបំណងនៃជំពូកនេះ ពាក្យ"ទំនិញ" និង "ផលិតផល" អាចត្រូវបានប្រើប្រាស់ជំនួសគ្នាទៅវិញទៅមក។

ច) **វត្ថុធាតុដូចគ្នានិងវត្ថុធាតុអាចផ្លាស់ប្តូរគ្នាបាន** មានន័យថា ជាវត្ថុធាតុដែលមានប្រភេទនិងគុណភាពពាណិជ្ជកម្មដូចគ្នា ដែលមានលក្ខណៈបច្ចេកទេសនិងរូបរាងដូចគ្នា ហើយដែលក្រោយពីបានដាក់

បញ្ចូលទៅជាផលិតផលសម្រេច មិនអាចត្រូវបានសម្គាល់ពីមួយទៅមួយសម្រាប់គោលបំណងកំណត់ពីដើមកំណើត តាមរយៈសញ្ញាសម្គាល់ណាមួយឬការពិនិត្យដោយភ្នែកជាទូទៅ ។ល។

ឆ) **វត្ថុធាតុ** មានន័យថា ជារូបធាតុឬសារធាតុទាំងឡាយ ដែលត្រូវបានប្រើប្រាស់ក្នុងផលិតកម្មនៃទំនិញ ឬត្រូវបានដាក់បញ្ចូលទៅក្នុងទំនិញផ្សេងទៀតឬត្រូវបានទុកដាក់កម្មវត្ថុទៅនឹងដំណើរការក្នុងផលិតកម្មនៃទំនិញផ្សេងទៀត។

ជ) **ទំនិញមិនមែនដើមកំណើតឬវត្ថុធាតុមិនមែនដើមកំណើត** មានន័យថា ជាទំនិញឬវត្ថុធាតុដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមលក្ខខណ្ឌដើមកំណើត ដោយអនុលោមតាមបទប្បញ្ញត្តិនៃជំពូកនេះ។

ឈ) **ទំនិញដើមកំណើតឬវត្ថុធាតុដើមកំណើត** មានន័យថា ជាទំនិញឬវត្ថុធាតុដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមលក្ខខណ្ឌដើមកំណើតដោយអនុលោមតាមបទប្បញ្ញត្តិនៃជំពូកនេះ។

ញ) **វត្ថុធាតុវេចខ្ចប់និងកុងតឺន័រសម្រាប់ការដឹកជញ្ជូន** មានន័យថា ជាទំនិញដែលត្រូវបានប្រើប្រាស់ដើម្បីការពារទំនិញក្នុងអំឡុងពេលដឹកជញ្ជូន ខុសពីកេស ឬសម្ភារៈដែលប្រើប្រាស់សម្រាប់ការលក់រាយ។

ដ) **ប្រព្រឹត្តកម្មអនុគ្រោះពន្ធគយ** មានន័យថា ការធ្វើសម្បទានពន្ធគយដែលត្រូវបានផ្តល់ចំពោះទំនិញដើមកំណើត ដូចបានឆ្លុះបញ្ចាំងដោយអត្រាពន្ធគយដែលអាចអនុវត្តបានក្រោមកិច្ចព្រមព្រៀងនេះ។

ឋ) **ផលិតកម្ម** មានន័យថា ជាវិធីសាស្ត្រក្នុងការទទួលបានទំនិញ រួមទាំងការដាំដុះ ការជីករ៉ែ ការប្រមូលផល ការចិញ្ចឹម ការបង្កាត់ពូជ ការចម្រាញ់ចេញ ការប្រមូលផ្តុំ វារីវប្បកម្ម ការប្រមូលយក ការចាប់យក ការនេសាទ ការដាក់អន្ទាក់ ការប្រមាញ់ កម្មន្តសាល ការផលិត ការកែច្នៃ ឬការផ្គុំទំនិញ និង

ឌ) **វិធានផលិតផលជាក់លាក់** មានន័យថា ជាវិធានដែលមានចែងនៅក្នុងឧបសម្ព័ន្ធ៣-២ (វិធានផលិតផលជាក់លាក់) ដែលបញ្ជាក់ថា វត្ថុធាតុដែលត្រូវបានប្រើប្រាស់ដើម្បីផលិត ទំនិញត្រូវបានផ្លាស់ប្តូរក្នុងចំណាត់ថ្នាក់ពន្ធគយ ឬការផលិតជាក់លាក់ ឬប្រតិបត្តិការកែច្នៃណាមួយ ឬឆ្លើយតបតាមលក្ខណៈវិនិច្ឆ័យនៃតម្លៃតំបន់ ឬការរួមបញ្ចូលគ្នានៃលក្ខណវិនិច្ឆ័យទាំងនេះ។

## មាត្រា៣

## លក្ខណាវិនិច្ឆ័យដើមកំណើត

សម្រាប់គោលបំណងនៃជំពូកនេះ ទំនិញដែលនាំចូលទៅក្នុងភាគីមួយចេញពីភាគីណាមួយទៀតត្រូវចាត់ទុកថាមានដើមកំណើត ប្រសិនបើទំនិញនោះអនុលោមតាមលក្ខខណ្ឌតម្រូវដើមកំណើត ដែលស្ថិតក្រោមលក្ខខណ្ឌណាមួយដូចខាងក្រោម៖

(ក) ទំនិញដែលទទួលបានទាំងស្រុងឬផលិតទាំងស្រុងនៅក្នុងភាគីនាំចេញ ដូចមានចែងក្នុងមាត្រា៤ (ទំនិញដែលទទួលបានទាំងស្រុងឬផលិតទាំងស្រុង)។

(ខ) ទំនិញដែលត្រូវបានផលិតទាំងស្រុងចេញពីវត្ថុធាតុដើមកំណើតនៃភាគីមួយ ឬច្រើន នៅក្នុងភាគីនាំចេញ ឬ

(គ) ទំនិញដែលមិនទទួលបានទាំងស្រុងឬមិនផលិតទាំងស្រុងក្នុងភាគីនាំចេញ ប្រសិនបើទំនិញនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចមានចែងក្នុងមាត្រា៥(ទំនិញដែលមិនទទួលបានទាំងស្រុងឬមិនផលិតទាំងស្រុង) និងបំពេញលក្ខខណ្ឌតម្រូវផ្សេងៗទៀតទាំងអស់នៃជំពូកនេះ។

## មាត្រា៤

## ទំនិញដែលទទួលបានទាំងស្រុងឬផលិតទាំងស្រុង

សម្រាប់គោលបំណងនៃវាក្យខណ្ឌ(ក) នៃមាត្រា៣ (លក្ខណវិនិច្ឆ័យដើមកំណើត) ទំនិញខាងក្រោមត្រូវបានចាត់ទុកថាទទួលបានទាំងស្រុងឬផលិតទាំងស្រុងនៅក្នុងភាគីនាំចេញ៖

ក) រុក្ខជាតិនិងទំនិញពីរុក្ខជាតិ រួមមាន ផ្លែឈើ ផ្កា បន្លែ ដើមឈើ រុក្ខជាតិតូចៗនៅក្នុងសមុទ្រ សារាយសមុទ្រនិងការដាំរុក្ខជាតិ ច្រូតកាត់ បេះ ឬប្រមូលផលនៅក្នុងភាគីមួយ[១]

ខ) សត្វរស់ ដូចជាថនិកសត្វ បក្សី ត្រី សត្វមានសម្បក សិប្បីសត្វ សត្វល្មូន បាក់តេរីនិងវីរុស ដែលបានកើតនិងចិញ្ចឹមនៅក្នុងភាគីមួយ

គ) ទំនិញដែលទទួលបានពីសត្វរស់នៅក្នុងភាគីមួយ

ឃ) ទំនិញដែលទទួលបានពីការបរបាញ់ ការដាក់អន្ទាក់ ការនេសាទ ការធ្វើកសិកម្ម វារីវប្បកម្ម ការប្រមូល ឬការចាប់ ដែលបានធ្វើឡើងក្នុងភាគីមួយ

ង) រ៉ែនិងសារធាតុកើតឡើងដោយធម្មជាតិផ្សេងទៀត ដែលមិនរាប់បញ្ចូលក្នុងវាក្យខណ្ឌ(ក) ដល់(ឃ) ដែលបានទាញយកឬយកចេញពីដី ទឹក បាតសមុទ្រឬក្រោមបាតសមុទ្រនៅក្នុងភាគីមួយ។

ច) ទំនិញដែលបានមកពីការនេសាទសមុទ្រ ដែលបានទាញយកឬយកចេញដោយនាវា ដែលបានចុះបញ្ជីជាមួយភាគីនាំចេញហើយមានសិទ្ធិលើកទង់ជាតិរបស់ភាគីនោះនិងរ៉ែ និងសារធាតុ ដែលកើតឡើងដោយធម្មជាតិដទៃទៀត ដែលត្រូវបានទាញយកឬយកចេញពីទឹក បាតសមុទ្រ ឬក្រោមបាតសមុទ្រនៅខាងក្រៅដែនទឹកនៃភាគីនាំចេញ លុះត្រាតែភាគីនោះមានសិទ្ធិទាញយកផលប្រយោជន៍ពីទឹក បាតសមុទ្រ និងក្រោមបាតសមុទ្រដោយអនុលោមតាមច្បាប់អន្តរជាតិ[២]

---

[១] សម្រាប់គោលបំណងនៃមាត្រា នេះ "នៅក្នុងភាគីមួយ " មានន័យថា៖

(i) សម្រាប់រដ្ឋសមាជិកអាស៊ាន ដែនដី ដែនសមុទ្រ តំបន់សេដ្ឋកិច្ចផ្ដាច់មុខតំបន់ខ្ពង់រាប ដែលភាគីមួយអនុវត្តអធិបតេយ្យ សិទ្ធិអធិបតេយ្យ ឬយុត្តាធិការលើភាពស្របតាមករណីដែលអាចមានដោយអនុលោមតាមច្បាប់អន្តរជាតិ។

(j) សម្រាប់ហុងកុង នៃប្រទេសចិន តំបន់នៃទីក្រុងហុងកុង នៃប្រទេសចិន។

សម្រាប់ចៀសវាងការសង្ស័យ គ្មានចំណុចណាមួយដែលមានចែងក្នុងនិយមន័យខាងលើត្រូវបានបកស្រាយថា ជាការទទួលស្គាល់ ឬការទទួលយកដោយភាគីមួយលើការទាមទារដែនសមុទ្រនិងដែនដី ដែលមិនច្បាស់លាស់ដែលបានធ្វើឡើងដោយភាគីមួយទៀតហើយក៏មិនត្រូវបានយកមកធ្វើឱ្យប៉ះពាល់លើការកំណត់នៃការទាមទារនោះបានឡើយ ។

[២] "ច្បាប់អន្តរជាតិ"សំដៅដល់ច្បាប់ដែលមានលក្ខណៈជាអន្តរជាតិដែលត្រូវបានគេទទួលយកជាទូទៅដូចជាអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីច្បាប់សមុទ្រ ឆ្នាំ១៩៨២។

ឆ) ទំនិញ ដែលបានមកពីការនេសាទសមុទ្រនិងបណ្តាទំនិញក្នុងសមុទ្រដទៃទៀត ដែលត្រូវបានយកពីដែនសមុទ្រទឹកជ្រៅដោយនាវា ដែលបានចុះបញ្ជីជាមួយភាគីមួយនិងមានសិទ្ធិលើកទង់ជាតិរបស់ភាគីនោះ។

ជ) ទំនិញកែច្នៃឬបានផលិតក្នុងបណ្តានាវារោងចក្រ ដែលបានចុះបញ្ជីជាមួយភាគីមួយឬមានសិទ្ធិលើកទង់ជាតិរបស់ភាគីនោះទាំងស្រុងចេញពីទំនិញទាំងអស់ ដែលមានចែងក្នុងវាក្យខណ្ឌ(ឆ)។

ឈ) ទំនិញទាំងឡាយណា ដែល៖

(i) ជាកម្ទេចនិងកាកសំណល់ ដែលបានមកពីផលិតកម្មនិងការប្រើប្រាស់នៅក្នុងភាគីមួយ ប្រសិនបើទំនិញនោះគឺសមស្របសម្រាប់តែគោលបំណងក្នុងការទាញយកវត្ថុធាតុដើម ឬការកែច្នៃយកមកប្រើឡើងវិញ ឬ

(ii) ជាទំនិញប្រើប្រាស់រួចដែលត្រូវបានប្រមូលនៅក្នុងភាគីមួយ ប្រសិនបើទំនិញនោះ គឺសមស្របសម្រាប់តែគោលបំណងក្នុងការទាញយកវត្ថុធាតុដើមឬការកែច្នៃយកមកប្រើឡើងវិញ និង

ញ) ទំនិញដែលទទួលបានឬផលិតនៅក្នុងភាគីនាំចេញ ចេញពីផលិតផល ដែលមានចែងក្នុងវាក្យខណ្ឌ (ក) ដល់ (ឈ)។

## មាត្រា៥

## ទំនិញដែលមិនទទួលបានទាំងស្រុងឬមិនផលិតទាំងស្រុង

១- លើកលែងតែទំនិញទាំងឡាយណាដែលមានចែងក្នុងកថាខណ្ឌ២សម្រាប់គោលបំណងនៃវាក្យខណ្ឌ (គ) នៃមាត្រា៣ (លក្ខណវិនិច្ឆ័យដើមកំណើត) ទំនិញត្រូវចាត់ទុកថាជាទំនិញដើមកំណើតប្រសិនបើទំនិញនោះមានសមាសធាតុតម្លៃតំបន់ ("Regional Value Content" ឬ "RVC") មិនតិចជាង ៤០ភាគរយ ដោយគណនាតាមរូបមន្ត ដូចមានចែងក្នុងមាត្រា៦ (ការគណនាសមាសធាតុតម្លៃតំបន់)។

២- ដោយអនុលោមតាមកថាខណ្ឌ១ ទំនិញដែលជាកម្មវត្ថុនៃវិធានផលិតផលជាក់លាក់ត្រូវបានចាត់ទុកថាជាទំនិញដើមកំណើត ប្រសិនបើទំនិញនោះបំពេញតាមលក្ខខណ្ឌវិធានផលិតផលជាក់លាក់ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ៣-២ (វិធានផលិតផលជាក់លាក់)៖

(ក) នៅពេលដែលវិធានផលិតផលជាក់លាក់ ផ្តល់នូវជម្រើសនៃវិធាននានាចេញពីវិធានដើមកំណើតផ្អែកលើ RVC ឬវិធានដើមកំណើតដែលផ្អែកលើការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធគយ ("CTC") ដំណើរការផលិតកម្ម ឬកែច្នៃជាក់លាក់ ឬការរួមបញ្ចូលគ្នានៃលក្ខណវិនិច្ឆ័យទាំងនេះ ភាគីនីមួយៗត្រូវអនុញ្ញាតឱ្យអ្នកនាំចេញទំនិញធ្វើការសម្រេចថាវិធានមួយណាដែលត្រូវប្រើប្រាស់ក្នុងការកំណត់ ថាតើទំនិញនោះមានគុណវុឌ្ឍិគ្រប់គ្រាន់ជាទំនិញដើមកំណើតរបស់ភាគីនោះ។

(ខ) នៅពេលដែលវិធានផលិតផលជាក់លាក់បញ្ជាក់ពី RVC ច្បាស់លាស់ នោះ RVC នៃទំនិញមួយត្រូវគណនាដោយប្រើរូបមន្តដូចមានចែងក្នុងមាត្រា៦ (ការគណនាសមាសធាតុតម្លៃតំបន់)។

(គ) នៅពេលដែលវិធានផលិតផលជាក់លាក់តម្រូវថាវត្ថុធាតុដែលត្រូវបានប្រើក្រោម CTC ឬដំណើរការផលិតកម្មឬកែច្នៃជាក់លាក់ វិធាននោះត្រូវអនុវត្តចំពោះតែវត្ថុធាតុណាមិនមែនដើមកំណើតប៉ុណ្ណោះ។

## មាត្រា៦

## ការគណនាសមាសធាតុតម្លៃតំបន់

១- សម្រាប់គោលបំណងនៃមាត្រា៥ (ទំនិញដែលមិនទទួលបានទាំងស្រុងឬមិនផលិតទាំងស្រុង) រូបមន្ត សម្រាប់គណនា RVC មានដូចខាងក្រោម៖

*(ក) វិធីផ្ទាល់/វិធីបង្កើនតម្លៃ (Build-up)*

$$RVC = \frac{\text{AHKFTA Material Cost} + \text{Direct Labour Cost} + \text{Direct Overhead Cost} + \text{Other Costs} + \text{Profit}}{\text{FOB Price}} \times 100\%$$

ឬ

*(ខ) វិធីប្រយោល/វិធីបញ្ចុះតម្លៃ (Build-down)*

$$RVC = \frac{\text{FOB Price} - \text{Value of Non-Originating Materials, Parts or Produce}}{\text{FOB Price}} \times 100\%$$

២- សម្រាប់គោលបំណងក្នុងការគណនា RVC ដែលមានចែងក្នុងកថាខណ្ឌ១៖

(ក) **ថ្លៃវត្ថុធាតុ AHKFTA** គឺជាតម្លៃនៃវត្ថុធាតុ បំណែក ឬផលិតផលដែលបានទទួលឬបានផលិតដោយខ្លួនឯង ដោយអ្នកផលិតក្នុងផលិតកម្មទំនិញនោះ។

(ខ) **តម្លៃវត្ថុធាតុ បំណែក ឬផលិតផលមិនមែនដើមកំណើត** គឺជាតម្លៃ CIF នៅពេលនាំចូល ឬថ្លៃដែលបានកំណត់ដំបូងបំផុតដែលបានទូទាត់លើវត្ថុធាតុ បំណែក ឬផលិតផលដែលមិនមែនដើមកំណើតនិងដែលបានទទួលដោយអ្នកផលិតនៅក្នុងផលិតកម្មទំនិញនោះ។ វត្ថុធាតុមិនមែនដើមកំណើត រួមបញ្ចូលទាំងវត្ថុធាតុពុំអាចកំណត់ដើមកំណើតបាន។

(គ) **ថ្លៃពលកម្ម** រួមមានប្រាក់ឈ្នួល សំណង និងអត្ថប្រយោជន៍ផ្សេងទៀតរបស់និយោជិត ដែលជាប់ទាក់ទងនឹងដំណើរការផលិតកម្ម។

(ឃ) **ថ្លៃចំណាយសរុប** រួមមានប៉ុន្តែមិនកំណត់ចំពោះតែអចលនទ្រព្យដែលជាប់ទាក់ទងជាមួយដំណើរការផលិតកម្ម (ធានារ៉ាប់រង ការជួលរោងចក្រ ការរម្លស់លើអគារ ការជួសជុលនិងថែទាំ ពន្ធ ការប្រាក់លើទ្រព្យបញ្ចាំ) ហើយចំណាយលើការជួល និងការទូទាត់ការប្រាក់សម្រាប់រោងចក្រនិងសម្ភារៈបរិក្ខារ សន្តិសុខរោងចក្រ ការធានារ៉ាប់រង (រោងចក្រ បរិក្ខារ និងវត្ថុធាតុ ដែលបានប្រើក្នុងការផលិតទំនិញ) ចំណាយផ្សេងៗ (ថាមពល អគ្គិសនី ទឹក និងចំណាយផ្សេងៗទៀតដែលពាក់ព័ន្ធនឹងផលិតកម្មទំនិញនោះដោយផ្ទាល់) ការស្រាវជ្រាវ ការអភិវឌ្ឍ ការរចនា និងវិស្វកម្ម ពុម្ព ឧបករណ៍និងការរម្លស់ ការថែទាំនិងការជួសជុលរោងចក្រ និងសម្ភារៈបរិក្ខារ សួយសារ ឬអាជ្ញាបណ្ណ (ទាក់ទងនឹងម៉ាស៊ីន ឬដំណើរការដែលមានប្រកាសនីយបត្រតក្កកម្ម ដែលបានប្រើប្រាស់ក្នុងការផលិតទំនិញ ឬសិទ្ធិផលិតទំនិញនោះ) អធិការកិច្ចនិងការធ្វើតេស្តវត្ថុធាតុនិងទំនិញ ការរក្សាទុក និងការចាត់ចែងនៅក្នុងរោងចក្រ ការគ្រប់គ្រងកាកសំណល់កែច្នៃឡើងវិញនិងសមាសភាគចំណាយផ្សេងទៀត ក្នុងការគណនាតម្លៃនៃវត្ថុធាតុដើម ឧទាហរណ៍ ការចំណាយលើផែនិងការជម្រះបញ្ជីនិងពន្ធនាំចូលដែលបានទូទាត់សម្រាប់សមាសភាគជាប់ពន្ធ និង

(ង) **ថ្លៃចំណាយផ្សេងៗ** គឺថ្លៃចំណាយលើការដាក់ទំនិញនៅក្នុងកប៉ាល់ឬមធ្យោបាយដឹកជញ្ជូនផ្សេងទៀតសម្រាប់ការនាំចេញ រួមមានថ្លៃដឹកជញ្ជូនក្នុងស្រុក ការស្តុកទុកនិងគ្រប់គ្រងឃ្លាំងទំនិញ ការគ្រប់គ្រងតាមកំពង់ផែ កម្រៃជើងសា និងថ្លៃសេវាកម្ម។

៣- តម្លៃទំនិញដូចបានចែងក្នុងជំពូកនេះ ត្រូវបានកំណត់ឡើងដោយអនុលោមតាមកិច្ចព្រមព្រៀងវាយតម្លៃពន្ធគយ។ បណ្តាភាគីត្រូវធ្វើសុខដុមនីយកម្ម នីតិវិធីនិងការអនុវត្តរដ្ឋបាលនៅក្នុងការវាយតម្លៃលើតម្លៃទំនិញសម្រាប់គោលបំណងគយតាមលទ្ធភាពដែលអាចធ្វើបាន។

## មាត្រា៧

## វិធានដើមកំណើតបូកបន្ថែម

លើកលែងតែមានចែងក្នុងកិច្ចព្រមព្រៀងនេះ ទំនិញដែលអនុលោមតាមលក្ខខណ្ឌដើមកំណើតដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ហើយដែលត្រូវបានប្រើប្រាស់នៅក្នុងភាគីផ្សេងទៀត ជាវត្ថុធាតុសម្រាប់ទំនិញសម្រេច ដែលអាចទទួលបានប្រព្រឹត្តកម្មអនុគ្រោះពន្ធគយ ត្រូវបានចាត់ទុកថាមានដើមកំណើតក្នុងភាគីចុងក្រោយ ដែលជាកន្លែងផលិតឬកែច្នៃទំនិញសម្រេចនោះ ត្រូវបានប្រព្រឹត្តទៅ។

## មាត្រា៨

## ប្រតិបត្តិការនិងដំណើរការអប្បបរមា

១- ថ្វីបើមានចែងក្នុងបទប្បញ្ញត្តិក្នុងជំពូកនេះ ទំនិញមួយមិនត្រូវបានចាត់ទុកថាមានដើមកំណើតនៅក្នុងដែនដីរបស់ភាគីមួយ ប្រសិនបើប្រតិបត្តិការខាងក្រោមត្រូវបានអនុវត្តទាំងស្រុងដោយឯកឯង ឬដោយរួមបញ្ចូលគ្នានៅក្នុងដែនដីនៃភាគីនោះ៖

(ក) ប្រតិបត្តិការរក្សាទុក ដើម្បីធានាថាទំនិញនៅតែមានស្ថានភាពល្អ អំឡុងពេលដឹកជញ្ជូន និងស្តុកទុក

(ខ) ការផ្លាស់ប្តូរនៃការវេចខ្ចប់ ការបំបែក និងការផ្គុំការវេចខ្ចប់

(គ) ការបោកគក់ ការលាងសម្អាត ការជម្រះសាមញ្ញ[៣] នូវធូលី អុកស៊ីដ ប្រេង ថ្នាំលាប ឬស្រទាប់ផ្សេងទៀត

(ឃ) ប្រតិបត្តិការសាមញ្ញ[៣] លើការបាញ់ពណ៌និងខាត់ឱ្យរលោង

(ង) ការយកសំបកចេញឬការស្រិត ជាផ្នែកឬទាំងស្រុងនិងការធ្វើឱ្យភ្លឺរលោងនូវធញ្ញជាតិ និងអង្ករ

(ច) ប្រតិបត្តិការដាក់ពណ៌ស្ករឬបង្កើតដុំស្ករ

(ឆ) ការចិត ការជំ ឬការបកសំបកសាមញ្ញ[៣]

(ជ) ការសម្រួច ការសំលៀងសាមញ្ញ[៣]និងការកាត់សាមញ្ញ[៣]

(ឈ) ការរែង ការចម្រាញ់ ការបែងចែកតាមប្រភេទ ការបែងចែកតាមចំណាត់ថ្នាក់ ការដាក់ចំណាត់ថ្នាក់ និងការផ្គូរផ្គង

(ញ) ការច្រកក្នុងដប កំប៉ុង ដបតូចៗ ថង់ កេស ប្រអប់ ការបិទភ្ជាប់កាត ឬបន្ទះក្តារ និងប្រតិបត្តិការវេចខ្ចប់សាមញ្ញ[៣]ដទៃទៀតទាំងអស់

(ដ) ការបោះត្រា ឬបោះពុម្ពសញ្ញា ស្លាកសញ្ញា រូបសញ្ញា និងសញ្ញាសម្គាល់ផ្សេងៗទៀតលើផលិតផល ឬកញ្ចប់ផលិតផលនោះ

(ឋ) ការលាយបញ្ចូលគ្នាសាមញ្ញ[៤] នៃផលិតផលទោះបីជាប្រភេទផ្សេងគ្នាក៏ដោយ

(ឌ) ការដំឡើងសាមញ្ញ[៣]នូវគ្រឿងបង្គុំដើម្បីបង្កើតបានជាទំនិញពេញលេញឬការបំបែកទំនិញទៅជាបំណែក

(ឍ) ការធ្វើតេស្តឬការតម្រែតម្រូវតាមខ្នាតសាមញ្ញ[៣]ឬ

(ណ) ការសម្លាប់សត្វ[៥] ។

---

[៣] "សាមញ្ញ" មានន័យថាសកម្មភាពដែលមិនត្រូវការជំនាញពិសេស គ្រឿងបរិក្ខារ ឬឧបករណ៍ដែលជាពិសេសត្រូវបានផលិត ឬដំឡើងសម្រាប់ធ្វើសកម្មភាព។

[៤] "ការលាយបញ្ចូលសាមញ្ញ" មានន័យថាជាសកម្មភាពដែលមិនត្រូវការជំនាញពិសេស គ្រឿងម៉ាស៊ីន ឬឧបករណ៍ដែលជាពិសេសត្រូវបានផលិត ឬដំឡើងសម្រាប់ធ្វើសកម្មភាព និងមិនរួមបញ្ចូលប្រតិកម្មគីមីឡើយ។ ប្រតិកម្មគីមីមានន័យថាជាដំណើរការមួយ(រួមទាំងដំណើរការគីមីជីវៈ) ដែលបណ្តាលឱ្យម៉ូលេគុលមួយដែលមានរចនាសម្ព័ន្ធថ្មីដោយបំបែកនូវចំណងអង់ក្រាម៉ូលេគុល និងដោយការបង្កើតជាចំណងអង់ក្រាម៉ូលេគុលថ្មី ឬដោយការផ្លាស់ប្តូរការរៀបចំទម្រង់អាតូមនៅក្នុងម៉ូលេគុលមួយ។

[៥] "ការសម្លាប់សត្វ" មានន័យថាជាការសម្លាប់សត្វ និងដំណើរការដោយបន្តបន្ទាប់ ដូចជាការកាត់ ភ្លាសេ បង្កក ប្រឡាក់អំបិល សម្ងួត ឬឆ្អើរ សម្រាប់គោលបំណងនៃរក្សាស្តុកទុក និងការដឹកជញ្ជូន។

២- ទំនិញដែលមានដើមកំណើតនៅក្នុងដែនដីរបស់ភាគីមួយ ត្រូវបានរក្សាស្ថានភាពដើមកំណើតដំបូងរបស់ទំនិញនោះ នៅពេលត្រូវបាននាំចេញពីភាគីមួយ ដែលប្រតិបត្តិការត្រូវបានធ្វើឡើងមិនលើសពីប្បញ្ញត្តិទាំងឡាយដែលចែងក្នុងកថាខណ្ឌ១។

## មាត្រា៩

## ការបញ្ជូនទំនិញដោយផ្ទាល់

១- ប្រព្រឹត្តកម្មអនុគ្រោះពន្ធគយត្រូវអនុវត្តចំពោះទំនិញ ដែលបំពេញបានតាមលក្ខខណ្ឌតម្រូវនៃជំពូកនេះ ហើយដែលត្រូវបានដឹកជញ្ជូនដោយផ្ទាល់រវាងភាគីនាំចេញនិងភាគីនាំចូល។

២- ខាងក្រោមនេះត្រូវចាត់ទុកថាជាការដឹកជញ្ជូនដោយផ្ទាល់ពីភាគីនាំចេញទៅភាគីនាំចូលៈ

ក- ទំនិញត្រូវបានដឹកជញ្ជូនពីភាគីនាំចេញទៅភាគីនាំចូល ឬ

ខ- ទំនិញត្រូវបានដឹកជញ្ជូនឆ្លងកាត់តាមភាគីមួយឬច្រើនក្រៅពីភាគីនាំចេញនិងភាគីនាំចូល ឬឆ្លងកាត់តាមភាគីមិនមែនហត្ថលេខី ក្នុងករណីដែលៈ

(i) ប្រកឆ្លងកាត់នោះ ត្រូវបានផ្ទៀងផ្ទាត់ដោយផ្អែកលើហេតុផលភូមិសាស្ត្រឬដោយការពិចារណាដែលទាក់ទងនឹងលក្ខខណ្ឌតម្រូវផ្នែកដឹកជញ្ជូន

(ii) ទំនិញដែលមិនសម្រាប់ការធ្វើពាណិជ្ជកម្ម ឬការប្រើប្រាស់នៅទីនោះនៅឡើយ និង

(iii) ទំនិញដែលមិនទាន់បានធ្វើប្រតិបត្តិការនៅទីនោះនៅឡើយ ក្រៅពីការលើកដាក់ឡើងចុះ ឬប្រតិបត្តិការផ្សេងទៀត ដើម្បីរក្សាទំនិញនោះស្ថិតក្នុងស្ថានភាពល្អ។

## មាត្រា១០

## អប្បបរមា ( De Minimis )

១- ទំនិញដែលមិនបំពេញតាមលក្ខខណ្ឌតម្រូវ CTC ត្រូវចាត់ទុកថាមានដើមកំណើតប្រសិនបើតម្លៃនៃវត្ថុធាតុមិនមែនដើមកំណើតទាំងអស់ ត្រូវបានប្រើប្រាស់ក្នុងផលិតកម្មនៃទំនិញនោះដែលមិនបំពេញតម្រូវ CTC មិនលើសពី១០ភាគរយនៃតម្លៃ FOB របស់ទំនិញនោះ ហើយទំនិញនោះបានបំពេញគ្រប់លក្ខណវិនិច្ឆ័យផ្សេងទៀតដែលមានចែងជាធរមាននៅក្នុងជំពូកនេះ ដើម្បីមានគុណវុឌ្ឍិគ្រប់គ្រាន់ជាទំនិញដើមកំណើត។

២- តម្លៃនៃវត្ថុធាតុមិនមែនដើមកំណើតដូចមានចែងក្នុងកថាខណ្ឌ១ ត្រូវបានរាប់បញ្ចូលនៅក្នុងតម្លៃនៃវត្ថុធាតុមិនមែនដើមកំណើតសម្រាប់លក្ខខណ្ឌតម្រូវ RVC ដែលអាចអនុវត្តបានចំពោះទំនិញនោះ។

## មាត្រា១១

## ប្រព្រឹត្តកម្មវេចខ្ចប់និងវត្ថុធាតុវេចខ្ចប់ និងកុងតឺន័រ

១- វត្ថុធាតុវេចខ្ចប់និងកុងតឺន័រសម្រាប់ការដឹកជញ្ជូននិងការដឹកទំនិញមិនត្រូវយកមកពិចារណាសម្រាប់ការកំណត់ដើមកំណើតទំនិញណាមួយឡើយ។

២- វត្ថុធាតុវេចខ្ចប់និងកុងតឺន័រសម្រាប់វេចខ្ចប់ទំនិញដើម្បីលក់រាយ ដែលត្រូវបានធ្វើចំណាត់ថ្នាក់ដោយអនុលោមតាមវិធាន៥ នៃវិធានទូទៅស្តីពីការបកស្រាយប្រព័ន្ធសុខដុមនីយកម្ម មិនត្រូវយកមកធ្វើជាមូលដ្ឋានក្នុងការកំណត់ដើមកំណើតទំនិញនោះទេ ក្នុងករណីដែលៈ

(ក) ទំនិញនោះទទួលបានទាំងស្រុងដូចមានចែងក្នុងវាក្យខណ្ឌ(ក) នៃមាត្រា៣ (លក្ខណៈវិនិច្ឆ័យដើមកំណើត)។

(ខ) ទំនិញនោះផលិតទាំងស្រុងនៅក្នុងដែនដីនៃភាគីមួយ ដូចមានចែងក្នុងវាក្យខណ្ឌ(ខ) នៃមាត្រា៣ (លក្ខណវិនិច្ឆ័យដើមកំណើត) ឬ

(គ) ទំនិញនោះគឺស្ថិតក្រោមលក្ខខណ្ឌតម្រូវ CTC ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ៣-២ (វិធានផលិតផលជាក់លាក់)។

៣- ប្រសិនបើទំនិញមួយស្ថិតក្រោមលក្ខខណ្ឌតម្រូវ RVC នោះតម្លៃនៃវត្ថុធាតុវេចខ្ចប់និងកុងតឺន័រសម្រាប់ការវេចខ្ចប់ទំនិញដើម្បីលក់រាយ ត្រូវយកមកពិចារណាថាជាវត្ថុធាតុដើមកំណើតឬមិនមែនដើមកំណើត ក្នុងការគណនា RVC នៃទំនិញនោះ តាមករណីនីមួយៗ។

## មាត្រា១២

## គ្រឿងបន្លាប់បន្សំ គ្រឿងបន្លាស់ និងឧបករណ៍

១- ប្រសិនបើទំនិញស្ថិតក្រោមលក្ខខណ្ឌតម្រូវ CTC ឬប្រតិបត្តិការផលិត ឬកែច្នៃជាក់លាក់ នោះដើមកំណើតនៃគ្រឿងបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និងឯកសារណែនាំឬឯកសារព័ត៌មានផ្សេងទៀតដែលត្រូវបានភ្ជាប់ជាមួយទំនិញនោះ មិនត្រូវយកមកពិចារណាធ្វើជាមូលដ្ឋានក្នុងការកំណត់ថាតើទំនិញមានគុណវុឌ្ឍិគ្រប់គ្រាន់ជាទំនិញដើមកំណើត ក្នុងករណីដែលៈ

(ក) គ្រឿងបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និងឯកសារណែនាំឬឯកសារព័ត៌មានផ្សេងទៀតមិនត្រូវបានដាក់ក្នុងវិក្កយបត្រដាច់ដោយឡែកពីទំនិញឡើយ និង

(ខ) បរិមាណនិងតម្លៃនៃគ្រឿងបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និងឯកសារណែនាំឬឯកសារព័ត៌មានផ្សេងទៀត ដែលទូទៅភ្ជាប់មកជាមួយទំនិញនោះ។

២- ប្រសិនបើទំនិញស្ថិតក្រោមវិធានដើមកំណើត RVC នោះតម្លៃនៃគ្រឿងបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និងឯកសារណែនាំឬឯកសារព័ត៌មានផ្សេងទៀត ត្រូវយកមកពិចារណាជាតម្លៃនៃវត្ថុធាតុដើមកំណើត ឬមិនមែនប្រភពដើម នៅក្នុងការគណនា RVC នៃទំនិញនោះ តាមករណីនីមួយៗ។

## មាត្រា១៣

## សមាសភាគអព្យាក្រឹត

ដើម្បីកំណត់ថាតើទំនិញនោះគឺជាទំនិញដើមកំណើតឬមិនមែនដើមកំណើតនោះ ពុំមានការចាំបាច់ដើម្បីកំណត់ដើមកំណើតនៃទំនិញខាងក្រោម ដែលអាចនឹងត្រូវបានប្រើប្រាស់នៅក្នុងផលិតកម្មនិងមិនត្រូវបានដាក់បញ្ចូលទៅក្នុងទំនិញនោះៈ

(ក) ប្រេងឥន្ធនៈនិងថាមពល

(ខ) ឧបករណ៍និងពុម្ព

(គ) គ្រឿងបន្លាស់និងវត្ថុធាតុដែលប្រើប្រាស់ក្នុងការថែទាំឧបករណ៍បរិក្ខារនិងអាគារ

(ឃ) ប្រេងរំអិល ខ្លាញ់គោ វត្ថុធាតុបន្សំ និងវត្ថុធាតុផ្សេងទៀតដែលប្រើប្រាស់ក្នុងផលិតកម្មឬប្រើប្រាស់ក្នុងដំណើការឧបករណ៍បរិក្ខារ និងអាគារ

(ង) ស្រោមដៃ វ៉ែនតា ស្បែកជើង សម្លៀកបំពាក់ គ្រឿងបរិក្ខារ និងសម្ភារៈផ្គត់ផ្គង់សុវត្ថិភាព

(ច) ឧបករណ៍បរិក្ខារនិងសម្ភារៈផ្គត់ផ្គង់ ដែលត្រូវបានប្រើប្រាស់សម្រាប់ការធ្វើតេស្តឬការធ្វើអធិការកិច្ចលើទំនិញនោះ

(ឆ) សារធាតុកាតាលីករនិងសារធាតុរំលាយ និង

(ជ) ទំនិញផ្សេងទៀតដែលមិនត្រូវបានបញ្ចូលទៅក្នុងទំនិញនោះប៉ុន្តែប្រើប្រាស់នៅក្នុងផលិតកម្មទំនិញនោះ អាចត្រូវបានបង្ហាញដោយមានហេតុផលសមរម្យថាជាផ្នែកមួយនៃផលិតកម្មនោះ។

## មាត្រា១៤

## វត្ថុធាតុដូចគ្នានិងវត្ថុធាតុអាចផ្លាស់ប្តូរគ្នាបាន

១- ការកំណត់ថាតើវត្ថុធាតុដូចគ្នានិងវត្ថុធាតុអាចផ្លាស់ប្តូរគ្នាបានគឺជាវត្ថុធាតុដើមកំណើត ត្រូវធ្វើឡើងដោយការបែងចែកជារូបវន្តនៃវត្ថុធាតុនីមួយៗឬដោយការប្រើប្រាស់ GAAP នៃការគ្រប់គ្រងស្តុកដែលអាចអនុវត្តបានឬវិធីគ្រប់គ្រងសារពើភណ្ឌនៅក្នុងភាគីនាំចេញ។

២- ក្នុងខណៈពេលណាមួយដែលការសម្រេចចិត្តត្រូវបានធ្វើឡើងចំពោះវិធីគ្រប់គ្រងសារពើភណ្ឌ វិធីនោះត្រូវយកមកប្រើនៅពេញមួយឆ្នាំសារពើពន្ធ។

## មាត្រា១៥

## វិញ្ញាបនបត្រដើមកំណើត

លើកលែងតែមានចែងនៅក្នុងជំពូកនេះ ការអះអាងថា ទំនិញមានលក្ខណៈគ្រប់គ្រាន់ដើម្បីទទួលបានប្រព្រឹត្តកម្មអនុគ្រោះពន្ធគយ ត្រូវបញ្ជាក់ដោយវិញ្ញាបនបត្រដើមកំណើត(ទម្រង់ AHK) ដែលចេញដោយអាជ្ញាធរចេញវិញ្ញាបនបត្រដែលចាត់តាំងដោយភាគីនាំចេញនិងត្រូវជូនដំណឹងដល់ភាគីផ្សេងទៀត ដោយអនុលោមតាមឧបសម្ព័ន្ធ ៣-១ (នីតិវិធីប្រតិបត្តិវិញ្ញាបនបត្រដើមកំណើត)។

## មាត្រា១៦

## ការធ្វើវិសោធនកម្មឧបសម្ព័ន្ធនិងសេចក្ដីបន្ថែម

១- យោងតាមអនុសាសន៍របស់អនុគណៈកម្មាធិការវិធានដើមកំណើត គណៈកម្មាធិការចម្រុះ AHKFTA អាចធ្វើវិសោធនកម្មជាលាយលក្ខណ៍អក្សរលើឧបសម្ព័ន្ធ៣-១ (នីតិវិធីប្រតិបត្តិវិញ្ញាបនបត្រដើមកំណើត) និងសេចក្ដីបន្ថែម (បញ្ជីទិន្នន័យត្រូវការចាំបាច់)។

២- ការធ្វើវិសោធនកម្មលើឧបសម្ព័ន្ធ៣-១ (នីតិវិធីប្រតិបត្តិវិញ្ញាបនបត្រដើមកំណើត) និងសេចក្ដីបន្ថែម (បញ្ជីទិន្នន័យត្រូវការចាំបាច់) ដែលបានអនុម័តដោយអនុលោមតាមកថាខណ្ឌ១ ត្រូវបោះផ្សាយឱ្យបានឆាប់រហ័សនិងត្រូវចូលជាធរមាននៅកាលបរិច្ឆេទ ដូចបានកំណត់ដោយបណ្ដាភាគីតាមរយៈគណៈកម្មាធិការចម្រុះ AHKFTA។

៣- យោងតាមអនុសាសន៍របស់អនុគណៈកម្មាធិការវិធានដើមកំណើត គណៈកម្មាធិការចម្រុះ AHKFTA ត្រូវអនុម័តលើការផ្ទេរបន្ទាត់ពន្ធគយ ដែលមាននៅក្នុងនាមវលីរបស់ប្រព័ន្ធសុខដុមដែលបានកែសម្រួលរួច ដោយស្របតាមវិសោធនកម្មជាទៀតទាត់របស់អង្គការគយពិភពលោកចំពោះនាមវលីនៅក្នុងប្រព័ន្ធសុខដុម ក្នុងឧបសម្ព័ន្ធ៣-២ (វិធានផលិតផលជាក់លាក់)។ ការផ្ទេរបន្ទាត់ពន្ធគយបែបនេះត្រូវអនុវត្តឡើងដោយមិនធ្វើឱ្យប៉ះពាល់ដល់ការសន្យាដែលមានស្រាប់និងត្រូវបញ្ចប់ឱ្យបានទាន់ពេលវេលា។

## មាត្រា១៧

## អនុគណៈកម្មាធិការវិធានដើមកំណើត

១- សម្រាប់គោលបំណងក្នុងការអនុវត្តជំពូកនេះឱ្យមានប្រសិទ្ធភាពនិងត្រឹមត្រូវ អនុគណៈកម្មាធិការវិធានដើមកំណើតត្រូវបានបង្កើតឡើង។

២- មុខងាររបស់អនុគណៈកម្មាធិការវិធានដើមកំណើតត្រូវ៖

(ក) តាមដានការអនុវត្តនិងប្រតិបត្តិការនៃជំពូកនេះ

(ខ) នៅពេលចាំបាច់ ពិនិត្យឡើងវិញលើជំពូកនេះដើម្បីផ្ដល់អនុសាសន៍សមស្របក្នុងគោលបំណងដើម្បីលើកកម្ពស់ឱ្យជំពូកនេះឆ្លើយតបទៅនឹងការប្រែប្រួលយ៉ាងឆាប់រហ័ស នៅក្នុងដំណើរការផលិតកម្មតំបន់និងពិភពលោក ដើម្បីជួយសម្រួលដល់ពាណិជ្ជកម្មនិងការវិនិយោគរវាងបណ្ដាភាគី ជំរុញបណ្ដាញផលិតកម្មតំបន់ លើកទឹកចិត្តដល់ការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ហើយកាត់បន្ថយគម្លាតអភិវឌ្ឍន៍

(គ) នៅពេលចាំបាច់ ពិនិត្យឡើងវិញលើនីតិវិធីប្រតិបត្តិនៃជំពូកនេះ ក្នុងគោលបំណងធ្វើឱ្យនីតិវិធីកាន់តែងាយស្រួលនិងមានតម្លាភាព អាចព្យាករណ៍បាននិងមានស្តង់ដា ដោយពិចារណាលើការអនុវត្តល្អបំផុតនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មតំបន់និងអន្តរជាតិផ្សេងទៀត

(ឃ) ពិចារណាលើបញ្ហាផ្សេងទៀតពាក់ព័ន្ធនឹងជំពូកនេះ ដែលបណ្ដាភាគីអាចឯកភាព និង

(ង) អនុវត្តមុខងារផ្សេងទៀត ដែលត្រូវបានធ្វើប្រតិភូកម្មដោយគណៈកម្មាធិការចម្រុះ AHKFTA ឬអង្គភាពជាន់ខ្ពស់ផ្សេងទៀត។

